BBI0076

# សម្ភាសន៍ជាមួយឈ្មោះម៉ាក់ សារិន ភេទប្រុស អាយុ៤៨ឆ្នាំ

មានស្រុកកំណើតនៅភូមិទទឹងថ្ងៃ ឃុំវាលពន្ធ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

សព្វថ្ងៃរស់នៅភូមិគគីរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង

សម្ភាសន៍ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១១

មុខងារសម័យខ្មែរក្រហមៈ ធ្វើការក្នុងក្រសួងឃ្លាំងរដ្ឋ

មុខងារបច្ចុប្បន្នៈ កសិករ

សម្ភាសន៍ដោយៈ ឡុង ដានី

សរុបទំព័រៈ ៣២

ដានីៈ អញ្ជើញដីបូនខ្ញុំសុំស្គាល់ឈ្មោះពូ តើពូឈ្មោះអីដែរ?

សារិនៈ ខ្ញុំឈ្មោះម៉ាក់ សារិន ។

ដានីៈ ពូមានអាយុប៉ុន្មានហើយ?

សារិនៈ អាយុ៤៨ ។

ដានីៈ សព្វថ្ងៃពូរស់នៅក្នុងភូមិឃុំអីដែរ?

សារិនៈ ភូមិអូរគគី ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

ដានីៈ ពូមានស្រុកកំណើតនៅណាដែរ?

សារិនៈ ភូមិទទឹងថ្ងៃ ។

ដានីៈ ពូនៅភូមិទទឹងថ្ងៃ?

សារិនៈ បាទ! ឃុំវាលពន្ធ ។

ដានីៈ ស្រុកខត្តុង?

សារិនៈ អត់ទេ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

ដានីៈ ចុះមីងគាត់ឈ្មោះអីដែរ?

សារិនៈ ឈ្មោះហែម សុខុម ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

សារិនៈ អាយុ៤៦ ។

ដានីៈ ស្រុកកំណើតគាត់រស់នៅណាដែរ?

សារិនៈ នៅភូមិស្វាយមេឡា ។

ដានីៈ ឃុំអី?

សារិនៈ ឃុំទ្រាល ។

ដានីៈ ស្រុក?

សារិនៈ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ដានីៈ សព្វថ្ងៃមុខរបរពូធ្វើអីដែរ?

សារិនៈ ធ្វើស្រែចំការហ្នឹង ។

ដានីៈ ពូធ្វើស្រែចំការ ហើយពូជាមេឃុំដែរ?

សារិនៈ បាទ!

ដានីៈ ពូធ្វើស្រែចំការហ្នឹងធ្វើអីខ្លះទៅ?

សារិនៈ ចំការដំឡូង ចំការពោត ចំការស្រូវ ។

ដានីៈ ហើយពូធ្វើមេឃុំអូរគគីហ្នឹងតាំងពីឆ្នាំណាមក?

សារិនៈ តាំងពីឆ្នាំ៩៧មក ។

ដានីៈ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

សារិនៈ មានកូន៥នាក់ ។

ដានីៈ ស្រីប៉ុន្មាន ហើយប្រុសប៉ុន្មាននាក់?

សារិនៈ ប្រុស៤នាក់ ហើយស្រីមានតែ១ម្នាក់ទេ ។

ដានីៈ កូនពៅអាយុប៉ុន្មានហើយ?

សារិនៈ កូនពៅអាយុ១៥ហើយ ។

ដានីៈ ចុះបងគេ?

សារិនៈ បងគេអាយុ២៥ហើយ ។

ដានីៈ អត់មានកូនរៀនទេ?

សារិនៈ កំពុងរៀន២នាក់ ។

ដានីៈ រៀននៅកំរៀងយើងហ្នឹង?

សារិនៈ បាទ!

ដានីៈ អត់ទាន់មានរៀនមហាវិទ្យាល័យទេ?

សារិនៈ អត់មានទេ ត្រឹមអនុវិទ្យាល័យហ្នឹង ។

ដានី៖    ពូឪពុករបស់ពូគាត់ឈ្មោះអីដែរ?

សារិន៖  គាត់ស្លាប់អស់ហើយ ។

ដានី៖    គាត់ស្លាប់ហើយ  តែគាត់ឈ្មោះអីទៅ?

សារិន៖  មិនដឹងដីតាគាត់ឈ្មោះអីទេ ។

ដានី៖    ចុះឈ្មោះរបស់គាត់?

សារិន៖  ឈ្មោះសែត ។

ដានី៖    គាត់ស្លាប់តាំងពីពេលណា?

សារិន៖  គាត់ស្លាប់តាំងពី៨២ ។

ដានី៖    ចុះម្ដាយ?

សារិន៖  ម្ដាយស្លាប់តាំងពី៩៩ ។

ដានី៖    គាត់ឈ្មោះអីដែរ?

សារិន៖  មៀក  កង ។

ដានី៖    ពូយកត្រកូលតាមម្ដាយវិញអញ្ចឹង?

សារិន៖  បាទ!

ដានី៖    ពូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

សារិន៖  មាន៥នាក់ ។

ដានី៖    ស្រីប៉ុន្មាន  ហើយប្រុសប៉ុន្មាននាក់?

សារិន៖  ស្រី២នាក់  ហើយប្រុស៣នាក់ ។

ដានី៖    ពូកូនទីប៉ុន្មាន?

សារិន៖  កូនទី១ ។

ដានី៖    បងគេបង្អស់?

សារិន៖  បាទ!

ដានី៖    ចុះកាលក្មេងៗពូមានបានរៀនសូត្រអត់?

សារិន៖  ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ហ្នឹង ។

ដានី៖    ថ្នាក់ទី១០ពីដើម?

សារិន៖  បាទ!

ដានី៖    នៅវត្តអីគេ?

សារិនៈ នៅវត្តរលាំងនាគ ។

ដានីៈ ឈប់ឆ្នាំណា?

សារិនៈ ឈប់ឆ្នាំ៧០ហ្នឹង កាលឆ្នាំ៧០ហ្នឹងគេបង្កើតឈ្លប បង្កើតនារីឈ្លបហើយក៏ឈប់រៀនទៅ ។

ដានីៈ ពេលពូឈប់រៀនពូធ្វើអី?

សារិនៈ នៅធ្វើស្រែចំការជាមួយម្ដាយឪពុករហូតដល់ឆ្នាំ៧៤ ។

ដានីៈ ហើយដល់ពេលឆ្នាំ៧៤ហ្នឹងពូធ្វើអីទៀតទៅ?

សារិនៈ ដល់ពេលចូលឆ្នាំ៧៥ យើងមានការរំដោះ ក្រោយពេលរំដោះហ្នឹងខ្ញុំមកនៅទីក្រុងភ្នំពេញនៅក្រសួងឃ្លាំងរដ្ឋ ។

ដានីៈ នៅក្រសួងឃ្លាំងរដ្ឋជាមួយអ្នកណាគេ?

សារិនៈ នៅជាមួយពូខ្ញុំឈ្មោះរឿង សម័យយើង៥ឆ្នាំ ។

ដានីៈ ពូបង្កើតមែន?

សារិនៈ បាទ! ពូបង្កើត ។

ដានីៈ រឿងហ្នឹងគាត់ប្រធានឃ្លាំងរដ្ឋ?

សារិនៈ ប្រធានក្រសួងឃ្លាំងរដ្ឋ ។

ដានីៈ គាត់នៅស្រុកកំណើតជាមួយលោកពូដែរ?

សារិនៈ បាទ! នៅជាមួយគ្នា ។

ដានីៈ កាលហ្នឹងពូអាយុប៉ុន្មានកាលមកនៅហ្នឹង?

សារិនៈ កាលហ្នឹងទើបតែអាយុ១៧ហ្នឹង ។

ដានីៈ កាលហ្នឹងឆ្នាំប៉ុន្មានពូ?

សារិនៈ មិនដឹង៥០ប៉ុន្មានទេ ខ្ញុំវាភ្លេចទៅខ្ញុំចាំតែឆ្នាំកំណើត ។

ដានីៈ ឆ្នាំកំណើតឆ្នាំណា?

សារិនៈ ឆ្នាំថោះ ។

ដានីៈ អញ្ចឹងពូមកនៅឃ្លាំងរដ្ឋជាមួយឪពុកមា កាលហ្នឹងគាត់ឲ្យធ្វើអីទៅ?

សារិនៈ កាលហ្នឹងធ្វើនារសា បើកឡានលិចកើតហ្នឹង ។

ដានីៈ កាលហ្នឹងមកតែពូតែម្នាក់ឬក៏មានបងប្អូនពូមកជាមួយដែរ?

សារិនៈ មកតែខ្ញុំម្នាក់ឯង ។

ដានីៈ ធ្វើនារសាបើកឡានឲ្យគាត់?

សារិនៈ បាទ!

ដានីៈ នៅកន្លែងណាទៅកាលហ្នឹង?

សារិនៈ នៅជិតវត្តខណ្ឌាឡោម គេហៅថាមន្ទីរចាត់ការឃុំងរដ្ឋហ្នឹង ។

ដានីៈ នៅក្នុងវត្តឬក៏នៅជិតទេ?

សារិនៈ អត់ទេនៅក្រៅវត្ត នៅខាងជើងវត្ត នៅកន្លែងបេស៊ីអ៊ីហ្នឹងហ្នង កន្លែងហ្នឹងគេដាក់បេស៊ីអ៊ីកន្លែងគេលក់ថ្នាំដុសធ្មេញ លក់ទឹកក្រូច ។

ដានីៈ កាលហ្នឹងពូធ្វើតែនារសាហើយបើកតែឡានអត់មានធ្វើអីទៀតទេ?

សារិនៈ បាទ!

ដានីៈ នារសាធ្វើអីខ្លះទៅ?

សារិនៈ រត់សំបុត្រ បញ្ជូនឯកសារទៅតាមកង ទៅតាមក្រសួងផ្សេងៗ ឧទាហរណ៍ក្រសួងពាណិជ្ជកម្មគេត្រូវការអី ក្រសួងឧស្សាហកម្មគេត្រូវការអីយើងគ្រាន់តែសារលិខិតហ្នឹងជូនឲ្យគេ ឧទាហរណ៍ថាក្រសួងពាណិជ្ជកម្មគេត្រូវការក្រណាត់ ក្រម៉ា បារីអញ្ចឹងយើងជូនឲ្យគេទៅតាមកងណា ឬក៏យើងទៅដឹកនៅកន្លែងក្រសួងឧស្សាហកម្មអញ្ចឹងទៅ យើងទៅយកពីឧស្សាហកម្មទៅទុកក្នុងឃ្លាំងអញ្ចឹងទៅ ទៅប្រមូលដូចជាអំបោះ ក្រម៉ា ក្រណាត់ក្នុងឃ្លាំង ឬក៏យើងគិតថាយើងនាំសារពីឃ្លាំងយើងទៅតាមក្រសួងអញ្ចឹងទៅ អាហ្នឹងគេហៅថារត់សារ ។

ដានីៈ កាលហ្នឹងឪពុកមារបស់ពូឈ្មោះរឿងហ្នឹងគាត់ធ្វើការនៅហ្នឹង?

សារិនៈ បាទ! គាត់ប្រធានក្រសួងហ្នឹង ។

ដានីៈ តួនាទីរបស់គាត់ជាមួយតារិទ្ធ?

សារិនៈ តារិទ្ធគាត់បែកទៅខាងពាណិជ្ជកម្ម ។

ដានីៈ តារិទ្ធបែកឆ្នាំណា?

សារិនៈ បែកឆ្នាំ៧៦ បែងចែកពីក្រសួងឃ្លាំងរដ្ឋហ្នឹង ។

ដានីៈ កាលពីមុននៅជាមួយគ្នា?

សារិនៈ នៅជាមួយគ្នា នៅជិតវត្តភ្នំ ។

ដានីៈ នៅជិតវត្តភ្នំ?

សារិនៈ បាទ! គាត់នៅជាមួយគ្នា ។

ដានីៈ នៅជាមួយគ្នា?

សារិនៈ ដល់ក្រោយមកឆ្នាំ៧៦ យើងទៅនៅជិតគាត់ទៀត ផ្ទះនៅជិតគ្នារំលងផ្លូវ តែគ្រាន់តែកន្លែងធ្វើការខុសគ្នា កន្លែងអីទ្វេពេលដែលគាត់បង្កើតក្រសួងពាណិជ្ជកម្មហើយគាត់ទៅនៅកណ្ដាលទីក្រុងភ្នំពេញ ។

ដានីៈ តួនាទីគាត់ប្រហែលគ្នា ប៉ុនគ្នា?

សារិនៈ ប្រហែលគ្នា តែបើយើងគិតថាពេលដែលយើងនៅក្នុងសង្គ្រាមហ្នឹងយើងអាចថាគាត់កាន់កងពល ។

ដានីៈ កាន់កងពល?

សារិនៈ បាទ! បើគាត់នៅពីសង្គ្រាមមកគាត់នៅសេដ្ឋកិច្ចភូមិភាគពិសេស ។

ដានីៈ មាររបស់ពូមែន?

សារិនៈ បាទ!

ដានីៈ គាត់នៅភូមិភាគពិសេស?

សារិនៈ ហ្នឹងអើយ ។

ដានីៈ ស្រុកកំណើតរបស់គាត់នៅជាមួយពូ?

សារិនៈ បាទ!

ដានីៈ សព្វថ្ងៃគាត់នៅទេ.

សារិនៈ គាត់ស្លាប់អស់ហើយ គាត់ស្លាប់នៅភ្នំដងរែក ។

ដានីៈ គាត់ឈឺ?

សារិនៈ បាទ!

ដានីៈ គាត់ស្លាប់ឆ្នាំណា?

សារិនៈ គាត់ស្លាប់ប្រហែលជាឆ្នាំ៨១, ៨២ហ្នឹង ។

ដានីៈ ចុះប្រពន្ធគាត់?

សារិនៈ ប្រពន្ធគាត់សព្វថ្ងៃទៅនៅស្រុកអត់ទាន់ស្លាប់ទេ គាត់ទៅនៅស្រុកជាមួយកូនប្រសារគាត់ ។

ដានីៈ ប្រពន្ធគាត់ចាស់ហើយ?

សារិនៈ ចាស់ហើយ អាយុគាត់៥០ជាងហើយ ។

ដានីៈ នៅណាទៅស្រុកប្រពន្ធគាត់?

សារិនៈ គេហៅស្អីទេភ្លេចបាត់ហើយ ។

ដានីៈ នៅក្នុងស្រុកកំរៀងយើងដែរ?

សារិនៈ អត់ទេនៅនោះនៅស្រុកកំណើត កាលគាត់ធ្វើសាមារណកម្មមាតុភូមិវិវត្តន៍លោកពូគាត់ទៅតាំងហ្នឹង ។

ដានីៈ ប្រពន្ធគាត់ឈ្មោះអីគេ?

សារិនៈ ឈ្មោះ សោ ។

ដានីៈ ប្រពន្ធគាត់បានការតាំងពីមុនឬក៏តាំងពីណាមក?

សារិនៈ ខ្ញុំមិនសូវដឹងដែរ គាត់ការបានកូនមួយកាលសម័យតស៊ូហ្នឹង កាលគាត់តស៊ូហ្នឹងមិនដឹងតាំងពីឆ្នាំណាទេ បើតាមខ្ញុំដឹងរឿងដូចជាឆ្នាំ៦៨ ។

ដានីៈ គាត់ការឆ្នាំ៦៨?

សារិនៈ អត់ទេគាត់ចូលតស៊ូ ។

ដានីៈ គាត់ចូលតស៊ូឆ្នាំ៦៨?

សារិនៈ ហើយ៦៩,៧០ហ្នឹងវាត្រូវពេញ ។

ដានីៈ កាលពីសម័យតស៊ូ៥ឆ្នាំហ្នឹងគាត់នៅសេដ្ឋកិច្ចភូមិភាគពិសេស ចុះកាលហ្នឹងតារិទ្ធគាត់ធ្វើអីដែរ?

សារិនៈ គាត់ភ្នាក់ងារខាងក្នុង ផ្តល់ពត៌មានខាងក្រៅ មានការទំនាក់ទំនងគ្នា ដល់ពេលគាត់បើកមុខបានគាត់រត់ចេញទៅក្រៅឆ្នាំ៧០ ។

ដានីៈ ដល់ពេលបែកឆ្នាំ៧៥ហើយបានគាត់មកធ្វើជាមួយគ្នា?

សារិនៈ ដល់ពេលដល់ឆ្នាំ៧៥ឆ្នាំរំដោះហ្នឹងគាត់បែកការណ៍បានគាត់រត់ចេញ ។

ដានីៈ ចុះកាលហ្នឹងក្នុងឃ្លាំងមានអីខ្លះទៅ?

សារិនៈ វាមានច្រើនយ៉ាងណាស់ ពីឆ្នាំ៧៧ដល់៧៨ តែសន្ទុះនៃការរីកចម្រើននៅក្នុងក្រសួងការរដ្ឋមានត្រឹមឆ្នាំ៧៧និង៧៨ មានសម្ភារៈគ្រប់យ៉ាង មានតាំងពីត្រាក់ទ័ មានតាំងពីគ្រឿងដែក ហើយសំណង់អីផ្សេងៗច្រើននាំមកពីប្រទេសចិននិងកូរ៉េ និងមានប្រទេសយូហ្គូស្លាវីដែរ មានឡានមានគ្រឿងម៉ាស៊ីន គ្រឿងចក្រអីផ្សេងៗ ។

ដានីៈ គ្រឿងចក្រមកពីកូរ៉េ?

សារិនៈ បាទ!

ដានីៈ ចុះមកពីចិនមានអីដែរ?

សារិនៈ ចិនក៏មានត្រាក់ទ័ដែរ ហើយមានសម្ភារៈដូចជាក្រណាត់ ។

ដានីៈ ពូធ្វើនារសាឲ្យគាត់រហូតដល់បែកឆ្នាំ៧៩ហ្នឹងហ្នង?

សារិនៈ បាទ! ដល់ឆ្នាំ៧៩ ហើយ៧៩ហ្នឹងនៅជាមួយគាត់រហូតទៀតដល់ឆ្នាំ៨០ ហើយបែកពីគាត់ខ្ញុំទៅនៅជាមួយអ៊ុំម៉ុត ។

ដានីៈ អ៊ុំម៉ុតហ្នឹងគាត់ធ្វើអី?

សារិនៈ អ៊ុំម៉ុតហ្នឹងគាត់កងពលដែរហ្នឹង តែគាត់នៅកងពលលេខប៉ុន្មានខ្ញុំអត់ដឹងទេណា៎ តែដល់ពេលចេញពីកោះកុងទៅនៅអន្លង់វែងហ្នឹងគាត់កាន់កងពល៧៨៥ ។ ។

ដានីៈ អ៊ុំម៉ុតហ្នឹង?

សារិនៈ ហ្នឹងអើយ គ្រួសារតាម៉ុកហ្នឹង ឥឡូវគាត់នៅសំឡូត ។

ដានីៈ កាលឆ្នាំ៧៥ហ្នឹងពូធ្វើការទាក់ទងជាមួយខាងក្រសួងឧស្សាហកម្មអញ្ចឹង?

សារិនៈ បាទ! ខ្ញុំរត់សាចុះឡើង ឧទាហរណ៍ថាក្រសួងឧស្សាហកម្មហ្នឹងមានតម្រូវការ ឧបមាថាក្រម៉ាប៉ុន្មានពាន់គីទៅ ហើយក្រណាត់ហ្នឹងប៉ុន្មានពាន់គីទៅ ហើយខាងបារីប៉ុន្មានពាន់អញ្ចឹងទៅណា៎ អញ្ចឹងអានេះជាតម្រូវការខាងឧស្សាហកម្ម ហើយធ្វើម៉េចឲ្យមានសម្ភារៈនៅក្នុងឃ្លាំង ហើយខាងអំបិល ខាងអង្ករយើងមានដឹកជូនទៅតាមភូមិភាគ ។

ដានីៈ បែកតាមភូមិភាគមួយៗ ។

សារិនៈ អញ្ចឹងកន្លែងក្រសួងឃ្លាំងហ្នឹងជាកន្លែងផ្ទុកសម្ភារៈម្យ៉ាងទាំងសំលៀកបំពាក់ ទាំងម្ហូបហូបចុក ។

ដានីៈ កាលនោះកម្មករច្រើនទេ?

សារិនៈ កម្មករហ្នឹងគ្រាន់តែស្រីហ្នឹងវាមានពីរវរៈសេនាតូចហើយដែលគេហៅថាវរៈ៧៧ ហើយប្រុសនៅវរៈ៧១,៧២,៧៣អញ្ចឹងវាមាន៥វរៈ ប្រុសៗមានបីវរៈហើយស្រីមានពីរវរៈ ស្រីៗខាងដេរប៉ាក់ដេរបាវអីហ្នឹង អញ្ចឹងកម្មករនៅក្នុងឃ្លាំងរដ្ឋហ្នឹងគឺគ្រាន់តែលីសម្ភារៈឡើងឡាន ឡើងរទេះភ្លើងអញ្ចឹងណា ត្រូវការស៊ីម៉ងត៍ ត្រូវការអំបិល ត្រូវការអង្ករអីទៅ ឬក៏ត្រូវការលើកកៅស៊ូ ទៅចិនទៅកូរ៉េទៅ ដូចប្រទេសណាមានទូតមានតែចិនហើយនឹងកូរ៉េ វាមានតែ៣ប្រទេសហ្នឹងទេដែល ខ្ញុំចាំ ។

ដានីៈ អញ្ចឹងក្រសួងឃ្លាំងរដ្ឋភាគច្រើនធ្វើការជិតស្និទជាមួយខាងក្រសួងពាណិជ្ជកម្ម?

សារិនៈ បាទ!

ដានីៈ ពូស្គាល់តារិទ្ធហ្នឹងច្បាស់ទេ?

សារិនៈ ស្គាល់ច្បាស់ ព្រោះតែអ្នកនៅជាមួយគាត់គឺច្បាស់ហើយ ។

ដានីៈ ចុះឈ្មោះហុង?

សារិនៈ ឈ្មោះហុងក្រោយទេ ឈ្មោះឆាយ

ឈ្មោះឆាយហ្នឹងកូនក្មួយឡាយហើយឡាយហ្នឹងក៏កូនក្មួយគាត់ដែរ អាហ្នឹងជិតស្និទបំផុតហើយ តែក្រៅពីហ្នឹងខ្ញុំអត់ស្គាល់ទេ ប្រហែលជាហុងហ្នឹងមួយដែរ តែគាត់ចាស់ ជាងឆ្ងាយ ។

ដានី: ចុះខាងពូមានតែពូម្នាក់ទេដែលធ្វើការជាមួយពូ?

សារិនៈ មានច្រើននាក់ដែរតែវាបែកបាក់គ្នាអស់ហើយ មានឈ្មោះដូចខ្ញុំហ្នឹងមួយទៀត?

ដានី: ឈ្មោះសារិនដែរ?

សារិនៈ បាទ! ហើយមានឈ្មោះឌុន ហើយមួយទៀតឈ្មោះស៊ីម អាហ្នឹងអ្នកក្នុងនារសាហ្នឹង ។

ដានី: សុទ្ធតែកូនក្មួយសាច់ញាតិ?

សារិនៈ អត់ទេ កូនក្មួយតែខ្ញុំមួយទេ កាលហ្នឹងសុទ្ធតែកម្មាំងតស៊ូ ។

ដានី: ចុះពួកគាត់រាល់ថ្ងៃគាត់នៅរស់ទេ?

សារិនៈ បែកគ្នាអស់ហើយមិនដឹងថាគេរស់ឬក៏ស្លាប់នោះទេ កាលពេល៧៩មកយើងបែកគ្នាអស់ហើយ អញ្ចឹងគេគិតថាចំណង់ចំណូលចិត្តរបស់គេ

គេចង់បែកទៅនៅកន្លែងផ្សេងទៅនៅអន្តភាពនេះអន្តភាព នោះ

ដូនកាលយើងនៅអន្តភាពខាងក្រោយវាពិបាកអញ្ចឹងគេចង់ទៅនៅតាមកង ។

ដានី: អញ្ចឹងតារិទ្ធគាត់ស្គាល់អីច្បាស់ហ្នង?

សារិនៈ ស្គាល់ច្បាស់ ។

ដានី: អាសារទៅធ្វើការនៅផ្ទះគាត់ ចុះកាលជំនាន់ហ្នឹងប្រពន្ធកូនគាត់ទៅនៅជាមួយពីណាគេ ហើយប្រពន្ធ ឈ្មោះអី?

សារិនៈ ឈ្មោះភាព ។

ដានី: កូនគាត់ធ្វើការនៅក្រសួងពាណិជ្ជកម្មដែរអត់ទេ?

សារិនៈ អត់ ។

ដានី: ចុះដល់ពេលប្រពន្ធរបស់ឪពុកមាពូគាត់ធ្វើអីគេ?

សារិនៈ គាត់អត់មានធ្វើអីទេនៅតែផ្ទះហ្នឹង ។

ដានី: ផ្ទះជិតគ្នាមែន?

សារិនៈ ទល់មុខគ្នា តែគាត់ពេលនេះទៅគាត់ទៅកន្លែងធ្វើការទៅហើយគាត់មកសម្រាកផ្ទះគាត់វិញ ។

ដានី: ពីណាគេ?

សារិនៈ អ៊ីរិទ្ធហ្នឹង ។

ដានី: ហើយចុះពេលហូបបាយហូបអី យើងហូបរួមជាមួយគាត់ឬក៏យើងបែកផ្សេង?

សារិនៈ ហូបរួមជាមួយគាត់ ។

ដានី: ដូចថាតារិទ្ធហើយឪពុកមាពូហូបជុំគ្នា?

សារិនៈ បាទ! អញ្ចឹងបានថាខ្ញុំពិបាកគាត់ហូបបាយយឺត ។

ដានី: ប្រពន្ធគាត់ហ្នឹង?

សារិនៈ បាទ! ជួនកាលយើងហូបមុនគាត់ឲ្យគាត់ហូបតែឯងក្រោយទៅ ។

ដានី: ប្រពន្ធគាត់ហើយតារិទ្ធគាត់ហូបយឺតដែរ?

សារិនៈ អត់ទេ តែប្រពន្ធគាត់ទេ ។

ដានី: គាត់ហូបម៉េចទៅ ហើយហូបរបៀបយ៉ាងម៉េច?

សារិនៈ ឧទាហរណ៍ថាបើសិនជាយើងគិតថាមិនបាច់ស្ងោរមាន់អញ្ចឹងគាត់ឲ្យស្ងោទាំងមូលហ្នឹង គាត់ឲ្យស្ងោរទាំង មូលហើយបេះ បេះហើយគាត់ឲ្យយើងយកបាយទៅដាំក្នុងអាឆ្នាំងស្ងោរមាន់ហ្នឹង កូរហើយអត់ឲ្យ ជាត់ពង្រីកទេឲ្យអាជីវជាតិមាន់នៅក្នុងហ្នឹងទាំងអស់ ដែលគេហៅថាបាយមាន់ៗនោះ ភាគច្រើន គាត់ហូបអញ្ចឹង បើកាលណាគាត់ហូបសម្លគឺមិនសូវនិយាយរួមាគាត់មិនចូលចិត្តសម្ល ចូល ចិត្តខាងចៀនខាងអាំងអញ្ចឹងទៅ ហើយសម្លបើគាត់អត់ហូបគាត់ដាំបាយមាន់អញ្ចឹងហ្នឹង យើងស្ងោរ មាន់ហើយបេះ បេះហើយលីង ។

ដានី: អាហ្នឹងប្រពន្ធរបស់តារិទ្ធ?

សារិនៈ បាទ!

ដានី: អញ្ចឹងពូធ្វើចុងភៅដែរ?

សារិនៈ អត់ទេម្ដាយមីងខ្ញុំតើ ។

ដានី: ប៉ុន្តែគាត់អ្នកប្រាប់ហូបអី ហើយគាត់ចង់ធ្វើអី?

សារិនៈ បាទ!

ដានី: ចុះខាងក្រសួងថាមពល ក្រសួងឧស្សាហកម្មអីពូស្គាល់ទេ?

សារិនៈ ខ្ញុំស្គាល់តែលោកអ៊ីវ៉ន វ៉េត ។

ដានី: ស្គាល់វ៉ន វ៉េតដែរ?

សារិនៈ បាទ!

ដានី: ស្គាល់គាត់ច្បាស់ទេ?

សារិនៈ ច្បាស់ ។

ដានីៈ ប្រពន្ធគាត់ឈ្មោះអីដែរ?

សារិនៈ អត់ស្គាល់ឈ្មោះប្រពន្ធទេ ។

ដានីៈ កាលហ្នឹងផ្ទះគាត់នៅជិតហ្នឹងដែរ?

សារិនៈ នៅម្តុំផ្សារថ្មី ។

ដានីៈ ចុះចេង អន ពូមានស្គាល់ទេ?

សារិនៈ ចេង អនក៏ស្គាល់ដែរ ។

ដានីៈ គាត់នៅជិតគ្នាដែរ?

សារិនៈ គាត់អត់នៅជិតគ្នាទេ គាត់នៅចំការមន ។

ដានីៈ ស្គាល់គាត់ច្បាស់ដែរ?

សារិនៈ បើថាស្គាល់ច្បាស់ដូចជាមិនសូវច្បាស់ទេ ព្រោះពេលនេះគណៈក្រសួងគេមិនទៅធ្វើការទាំងអស់គ្នា ហើយយើងមិនទៅ ហើយមិនដឹងមកពីខាងណាៗ មានភូមិភាគនារតី ភូមិភាគបច្ចឹម ភូមិភាគពាយ័ព្យ ហើយមានក្រសួងឧស្សាហកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងថាមពល ។

ដានីៈ ក្រសួងថាមពលរបស់ពីណាគេ?

សារិនៈ របស់ពីណាគេទេ?

ដានីៈ មេបារាំងមែនទេ?

សារិនៈ ខ្ញុំភ្លេចទៅហើយ ប៉ុន្តែគាត់នៅម្តុំឬស្សីកែវដែរហ្នឹង នៅកន្លែងកាវ៉ាស់ធំ ។

ដានីៈ ទួច ភឿនមែន?

សារិនៈ ទេគេហ្នឹងមិនដឹងឈ្មោះអីភ្លេចបាត់ហើយ នៅចុងៗមាត់ ហើយមកចែកកាំភ្លើងនៅសាលាក្រោមបាញ់គ្នាជាមួយប៉ៃលិន ភ្លេចបាត់ហើយយូពេក ប្រធានក្រសួងថាមពល គាត់គ្រប់គ្រងខាងផ្នែកខស្ទ័នហ្នឹង ។

ដានីៈ ខាងភ្លើង?

សារិនៈ ខាងប្រេង អញ្ចឹងពេលយើងត្រូវការប៉ុន្មានយើងគេទៅគាត់ទៅ ។

ដានីៈ ត្រូវចាក់ឡានចាក់អី?

សារិនៈ បាទ! គាត់ហ្នឹងគាត់ត្រូវដឹកទៅក្រសួងដើងគោក ហើយមានខាងដើងទឹកអញ្ចឹងទៅគាត់ដឹកទៅដាក់នៅ ខាងក្រសួងពាណិជ្ជកម្មអញ្ចឹងទៅ គាត់ដើរតែដឹញដាក់ហ្នឹង ខ្ញុំភ្លេចឈ្មោះបាត់ហើយបងខ្ញុំមួយ នៅហ្នឹងដែរ ។

ដានី: គាត់អ្នកស្រុកណា?

សារិនៈ ខ្ញុំអត់មានបានសាកសួពីរឿងស្រុកទេ ស្គាល់តាមរយៈពូហ្នឹង ហើយម្យ៉ាងទៀតកាលនោះគាត់អ្នកធំៗផងមិនសូវហ៊ានទំនាក់ទំនងទេ តែគាត់ចេះតែហ៊ានហើយតែយើងក្មេងមិនសូវមានការទំនាក់ទំនងទេ គាត់ចាស់ទុំហើយយើងមិនសូវហ៊ានលេងសើចជាមួយគាត់ទេ វាអត់ទំនងទេ ។

ដានី: ពូមានដែលធ្លាប់ជួបអ៊ីៗដូចជាអ៊ីប៉ុល ពត, អៀង សារី, នួន ជាអីទេ?

សារិនៈ ជួបតែពេលធ្វើការអញ្ចឹងទេ ពេលទៅធ្វើសន្និបាតអីម្ដងម្កាលហ្នឹង តែបើឲ្យទៅជួបនៅផ្ទះគាត់មិនដែលបានជួបទេ ។

ដានី: ដូចថាពេលឪពុកមាពូគាត់ទៅពូមានដែលទៅជាមួយទេ?

សារិនៈ ហ្នឹងពេលគាត់ទៅប្រជុំគាត់ហៅទៅជាមួយអញ្ចឹងទៅ ទៅស្ពាតអញ្ចឹងទៅ ហើយទៅផ្សារអូឡាំពិក ទៅផ្សារដើមគរពេលដែលមានពិធីអញ្ចឹងណា ឬទៅប្រជុំនៅវាំងអញ្ចឹងទៅ ។

ដានី: បាទ!

សារិនៈ ទៅហ្នឹងវាចាំមិនអស់ទេ មេមួយឡានមួយ ។

ដានី: មេមួយឡានមួយ?

សារិនៈ បាទ!

ដានី: ពូស្គាល់អ៊ឹ ជៀមទេ?

សារិនៈ តា ជៀម ស្គាល់?

ដានី: ពូស្គាល់ដែរ?

សារិនៈ តាជៀមយើងនេះ?

ដានី: ជៀម ខាងម៉ាឡៃ?

សារិនៈ ហ្នឹងអើយ ។

ដានី: ស្គាល់គាត់តាំងពីជំនាន់ហ្នឹងឬក៏ជំនាន់ក្រោយ?

សារិនៈ ស្គាល់នៅ៨០៨ កាលមុនគាត់នៅ៨០៨ ដល់ពេលគាត់ដកពី៨០៨មកនៅនេះវិញ ។

ដានី: ៨០៨នៅណាទៅ?

សារិនៈ នៅដងរែក ។

ដានី: ខាងដកវែកវិញ?

សារិនៈ ខាងអន្លង់វែងនោះ ។

ដានី៖ តាំងពីឆ្នាំ៨០ដាងប៉ុក៏ម៉េច?

សារិន៖ តាំងពីឆ្នាំ៧៩ ។

ដានី៖ ៧៩?

សារិន៖ បាទ! កាល៧៩គាត់នៅហ្នឹង ទើបតែគាត់ដកមកឆ្នាំ៨០ដាង ។

ដានី៖ គាត់មកខាងម៉ាឡៃវិញ?

សារិន៖ បាទ! គាត់មកខាងម៉ាឡៃវិញ ។

ដានី៖ ខ្ញុំធ្លាប់ជួបគាត់កាលប៉ុន្មានខែមុន ។

សារិន៖ ខ្ញុំភ្លេចអស់ហើយមេៗដែលធ្លាប់ស្គាល់ ពិសេសមនុស្សដែលធ្លាប់នៅមន្ទីរជាមួយគ្នាខ្ញុំភ្លេចគេអស់ហើយ ។

ដានី៖ យូពេក?

សារិន៖ យូពេក ហើយបងៗខ្ញុំខ្លះស្គាល់គាត់តែគាត់អត់ស្គាល់ខ្ញុំទេ ខ្ញុំហៅគាត់តែគាត់ថាអានេះមិនដឹងពីណាគេទេ ។

ដានី៖ យូពេក ។

សារិន៖ ទាល់តែនិយាយរឿងហេតុពីដើមទាក់ទងយើងរស់នៅឯណាៗ បានគាត់ថាអាប្រកាច់ឯងចាស់ម្ល៉េះឥលូវ ។

ដានី៖ ចូល២០,៣០,៤០ឆ្នាំហើយ ។

សារិន៖ កាលហ្នឹងគាត់អាយុ៣០ហើយខ្ញុំទើបតែ១៨ឆ្នាំហ្នឹង ហើយដល់ពេលអញ្ចឹងអត់សូវស្គាល់គាត់អស់ទេ ។

ដានី៖ ចុះពូកាលហ្នឹងនៅក្នុងសម័យ៣ឆ្នាំពូអត់ទាន់មានប្រពន្ធទេ?

សារិន៖ អត់ទេ ទើបតែមានឆ្នាំ៨៧នេះហ្នឹង ។

ដានី៖ ទើបតែ៨៧ហើយទេ?

សារិន៖ បាទ!

ដានី៖ អញ្ចឹងកាលពេលយួនចូលមកឆ្នាំ៧៩ហ្នឹងពូរត់យ៉ាងម៉េចដែរ?

សារិន៖ កាលហ្នឹងខ្ញុំធ្វើដំណើរតាមអង្គភាពហ្នឹងឯង តាមក្រសួងរបស់ខ្ញុំហ្នឹងដោយឡាន កាលហ្នឹងមានឡានច្រើនណាស់បើយើងនិយាយជាឡាននោះ អញ្ចឹងយើងយកពីក្រសួងដើងគោក៨,៩គ្រឿងមកយើងមានគ្រៀមអង្ករ គ្រៀមឆ្នាំ គ្រៀមប្រហុកអំបិលអីហ្នឹងច្រើន តែគ្រាន់តែឡានគេចេញមកបាត់ៗ ហើយយើងមានទំនុកបំរុងហ្នឹងចេះតែចាំគេ គេចេញទៅបាត់មិនដឹងគេទៅតាម

ផ្លូវណាទេ អាហ្នឹងឡានរបស់ក្រសួង បើឡានរបស់ខ្លួនឯងស្រួលចេញមកទាំងអស់គ្នា តែវាបែកបាក់ដែរ ព្រោះគេមានបែងចែកថាឡានខ្លះត្រូវនៅទីក្រុងភ្នំពេញ ហើយខ្លះទៀតយើងត្រូវបញ្ជូនទៅឲ្យកងទ័ព ទៅខាងបងលួយ ព្រោះបងលួយហ្នឹងគាត់ប្រធានកងពល ដូច៥០២អញ្ចឹង ហើយភូមិភាគពិសេសអីក៏មិនដឹងនៅណាដែរ អញ្ចឹងយើងបានមកនេះមកជាប់នឹងគាត់ប្រហែល ៣០០នាក់ ។

ដានី: ជាប់ជាមួយពីណាគេ?

សារិន: ជាប់ជាមួយពូខ្ញុំហ្នឹង ពូរឿង ជាប់មករហូតតាំងពីចេញពីភ្នំពេញមកដល់អមលាំង ចេញពីអមលាំងដល់យើងបវេល ចេញពីនោះមកបវេល នៅបវេលប្រមូលស្រូវបាន១ជ្រាំង ដល់ហើយបានមានសភាពការណ៍ទាហានបុកមកទៀត យួនបុកមកទៀត យើងរៀបចំកំលាំងទៅជាកងទ័ព បង្កើតទ័ព បើកអាវុធបង្កើតទ័ព បងអីភ្លេចបាត់ បានមកវៃគ្នានៅសាលាក្រៅ វៃគ្នានៅកំរៀងយើងហ្នឹង វៃគ្នានៅបវេល ហើយកងទ័ពវៀតណាមចេះតែដេញមក យើងចេះតែរត់មក រត់ៗមកចោលឡាននៅយើងចក្រីនេះ ចោះឡានចោលហ្នឹង ឡានដឹកអង្ករ ដឹកឥវ៉ាន់ហូបហ្នឹង អាហ្នឹងជម្រុះចោលហើយ សម្ភារៈណាដែលយកមិនរួច យកតែមួយរួចទៅតាមខ្លួនមកជួបជុំគ្នាចូលនៅបឹងឆ្នាំង ។

ដានី: បឹងអី?

សារិន: អាបឹងឆ្នាំងយើងនេះ ភូមិបឹងឆ្នាំងថៃនេះ កន្លែងយើងជិតស្ពានកំរៀងនេះ នៅភ្នំព្រះពុទ្ធ ទៅនៅភ្នំព្រះពុទ្ធហ្នឹងពួកខ្ញុំកាល៧៩ នៅអ៊ំ រិទ្ធ, អ៊ំ រឿង នៅ២នាក់គ្នាគាត់ ។

ដានី: អ៊ំ រិទ្ធ, អ៊ំ រឿង?

សារិន: បាទ! ហើយបង ស គុណវុធ នោះគាត់ខាងទំនាក់ទំនងខាងស្ពានទូត ។

ដានី: បងអីគេ?

សារិន: បង ស គុន្និមុត ។ ដែលមានរឿងចោទគាត់ ហ្នឹងគាត់ទំនាក់ទំនងទូត ទាក់ទងអង្ករ ស្លឹកគ្រៃអីមកចិញ្ចឹមពួកអ៊ំ រិទ្ធ ។

ដានី: ម៉េចទៀតទៅពូ?

សារិន: ដល់មកនៅហ្នឹងទៅគេចេះតែដេញយើង ហើយយើងចូលទៅនៅថៃ ទៅនៅសាងសង់ជំរុំទៅនៅខាងនោះត្រាង ដីថៃ ដល់ពេលយើងទៅនៅហ្នឹងបាន៣-៤ខែ ២-៣ខែវាដកពីហ្នឹងទៅចេះតែរំកិលទៅតាមព្រំដែនរហូត យើងទៅនៅក្រាំងផ្លាក់ទៅភូមិដូងនោះ បឹងត្រកួន ។

ដានី: ភូមិដូងណា?

សារិនៈ បឹងត្រកួន ភូមិដូងហ្នឹងឯង ។

ដានីៈ បឹងត្រកួនទៅខាង?

សារិនៈ ម៉ាឡៃយើងហ្នឹង ទៅពីហ្នឹងទៅ ទៅដល់ហ្នឹង អ៊ឹ រិទ្ធ គាត់ថាយើងមកនៅនេះលំបាកដល់ហើយ ទៅនៅដងរែកទៅ បានធ្វើការទំនាក់ទំនង ដល់ហើយទៅក៏ចេញពីហ្នឹងទៅ ទៅនៅបឹងត្រកួនបាន ប៉ុន្មានខែទេ បានយើងសំរេចចិត្តថាទៅនៅដងរែក អីចឹងក៏ទៅនៅដងរែកហ្នឹងរហូតទៅ ទៅនៅ បានប៉ុន្មានឆ្នាំទេ ឆ្នាំ ។

ដានីៈ ទៅនៅដងរែក ទៅនៅជាមួយតា សុន សែន វិញ?

សារិនៈ នៅជាមួយ តាម៉ុក តែយើងគិតថា យើងនៅនេះមានការគ្រប់គ្រងរបស់ បងគិន អីចឹង ។

ដានីៈ បងអីគេ?

សារិនៈ បងសុបិន បងបិនៗ ដល់នៅនោះការគ្រប់គ្រងរបស់ បងសឿន តែការគ្របដណ្តប់ពីខាងលើ មកមាន តាម៉ុក ហ្នឹងឯង ។

ដានីៈ គ្រប់គ្រងរបស់បងអី បងសេ?

សារិនៈ បងសឿន ។

ដានីៈ បងសឿន ហេ៎!

សារិនៈ បងសឿន ហ្នឹងនៅខាង ៨០៨ ហ្នឹង បងសឿន ហ្នឹងនៅក្រោយទេ គិតថា បងជៀម គាត់មកនេះវិញ កាលមុន បងជៀម គាត់នៅកាលខ្ញុំទៅដល់ដំបូងហ្នឹង បងជៀម នៅហ្នឹង ដល់ពេល បងជៀម មកនេះទៅបានឡូ បងសឿន អ្នកគ្រប់គ្រង ។

ដានីៈ ក្រោមរបស់ តាម៉ុក ដដែរ?

សារិនៈ បាទ! នៅការគ្រប់គ្រងរបស់ តាម៉ុក ដដែរ ។

ដានីៈ នៅដងរែកហ្នឹងនៅម្តុំណា?

សារិនៈ នៅច្រើនកន្លែង យើងគិតថាជីវិតរស់នៅរបស់យើង វាដូចតែឈូសហ្នឹងមិនខុសគ្នាទេ រកស៊ី នៅនេះមាន សេចក្តីសុខនៅ ដល់ពេលមានឧបសគ្គ មានគេបៀតបៀនរត់ទៅនៅមួយកន្លែង ទៀតទៅ ដើរតែនៅក្នុងព្រៃរហូតទៅណា៎ ជីវិតតស៊ូ រហូតដល់ពេលយើង ។

ដានីៈ កាលហ្នឹងពូជួប ពូប៉ូច នៅណាដែរ?

សារិនៈ នៅឆ្នាំ៨២-៨៣ហើយ បងប៉ូច គាត់ក៏មកពីខាងភូមិភាគកណ្តាលមក មកពីខាងយើងក្រចេះ ស្ទឹងត្រែង អីចឹងឡើងមកជុំគ្នានៅដងរែកហ្នឹងឯង ។

ដានីៈ អ៊ំប៉ូច កាលហ្នឹងគាត់ធ្វើអី? កាលហ្នឹងគាត់មកជួប?

សារិនៈ កងពលដែរ ។

ដានីៈ គាត់គួនាទីគាត់កងពលដែរ?

សារិនៈ បាទ! ៤១៦ ។

ដានីៈ គាត់នៅ៤១៧?

សារិនៈ បាទ!

ដានីៈ ជួបនៅក្នុងកងពលដែរ តែពូនៅក្នុងពលផ្សេង?

សារិនៈ ខ្ញុំនៅកងពលផ្សេង ។

ដានីៈ កងពលរបស់ពូកាលហ្នឹងកងពលអីគេ?

សារិនៈ កងពលរៀបថ្មីហ្នឹងកាលហ្នឹងគេហៅកងពល៩៨០ ។

ដានីៈ ពីណាគេប្រធាន?

សារិនៈ មុត ហ្នឹងប្រធាន ។

ដានីៈ មុតហ្នឹងប្រធាន?

សារិនៈ បាទ! ប្រធានកងពល៩៨០ តែដល់ក្រោយមកទៀតបានកងពល៩៨០ហ្នឹងបំបែកខ្លួនចេញទៅរៀបចំជាកងពលមួយទៀតគេហៅថាកងពល៧៨៥ អញ្ចឹងធ្វើនៅថ្ងៃទី៧ ។

ដានីៈ ឆ្នាំ១៩៨៥?

សារិនៈ ខែ៧ ដល់ហើយគេហៅថាកងពល៧៨៥ហ្នឹងទៅ ។

ដានីៈ កាលហ្នឹងពូជួបជាមួយអ៊ំ ប៉ុចហ្នឹងតែម៉ានេះហ្នឹងឬក៏បាននៅជាមួយគាត់?

សារិនៈ អត់បាននៅជាមួយគ្នាទេ តែគ្រាន់តែដឹងថាខ្ញុំហើយនឹងគាត់ហ្នឹងបាននៅជិតៗគ្នាហ្នឹង គាត់នៅអន្លក់ភាពនោះម៉្តុំទៅ ហើយខ្ញុំនៅអន្លក់ភាពនេះម៉្តុំទៅ តែដឹងថាបាននៅជិតៗគ្នា ។

ដានីៈ ដឹងថាស្រុកកំណើតនៅជិតៗគ្នាដែរ?

សារិនៈ ស្រុកកំណើតនៅជិតៗគ្នាដែរហ្នឹង ។

ដានីៈ ស្គាល់គាត់តាំងពីមុនហ្នឹងឬក៏ទើបតែស្គាល់ទេ?

សារិនៈ បងខ្ញុំគាត់នៅជាប់តែម្តង បងខ្ញុំគាត់នៅជាប់ជាមួយអ៊ំ ប៉ុចហ្នឹង ។

ដានីៈ អញ្ចឹងបងរបស់ពូ.?

សារិនៈ បងខ្ញុំ ថន ហ្នឹងជីដូនមួយបង្កើតគាត់នៅជាប់តែម្តង ។

ដានីៈ នៅជាមួយអ៊ំ ប៉ុចហ្នឹងតាំងពីគាត់ទៅកាន់នៅភូមិភាគកណ្តាល?

សារិនៈ បាទ!

ដានី: គាត់ទៅធ្វើគណៈស្រុកនៅកំពង់ធំ?

សារិនៈ បាទ!

ដានី: អញ្ចឹងបងរបស់ពូគាត់ទៅនៅជាមួយ?

សារិនៈ ឥលូវគាត់បែកហើយ ឥលូវគាត់ទៅធ្វើមេភូមិនៅជិតអូរស្វាយ ។

ដានី: អូរស្វាយនៅអន្លង់វែងដែរ?

សារិនៈ នៅអន្លង់វែងដែរ ។

ដានី: អញ្ចឹងពូស្គាល់គាត់តាំងពីនៅស្រុកកំណើត?

សារិនៈ អត់ដែលស្គាល់ទេ ។

ដានី: ចុះតា អាន ពូស្គាល់គាត់តាំងពីពេលណា?

សារិនៈ តាំងពីយើងមកជួបគ្នាដំបូង ខ្ញុំផ្លាស់ពី៧៨៥ ទៅនៅ៩២០ ។

ដានី: ដល់ទៅ៩២០ បានស្គាល់គាត់?

សារិនៈ បាទ! កាលមុនគាត់នៅនេះ ហើយគាត់នៅខាងកើតនៅខាង១២០០ ។

ដានី: នៅខាង១០០២?

សារិនៈ នៅខាង១០០២ហ្នឹងខាងរាជរដ្ឋាភិបាល ចេះតែពង្រួញទឹកដីដែលខ្មែរក្រហមកាន់កាប់ ដល់ពេលរួញទៅៗ យើងចេះតែមកស្គាល់ទេ ។

ដានី: ១០០២នៅម្ដុំណា?

សារិនៈ កន្លែងយើងព្រះវិហារហ្នឹង ។

ដានី: កន្លែងព្រះវិហារទន្លេល្ពៅហ្នឹង?

សារិនៈ ហ្នឹងអើយ ។

ដានី: កាលហ្នឹងគាត់នៅហ្នឹងទេ?

សារិនៈ ហ្នឹងហើយ ។

ដានី: គាត់ធ្វើអីកាលនោះ?

សារិនៈ ខ្ញុំអត់ដឹងថាគាត់ធ្វើអីនោះទេ តែគាត់នៅជាប់ជាមួយខាងលើហ្នឹងណា៎ ។

ដានី: កាលហ្នឹងពូមានដឹងថាគាត់នៅភូមិភាគកណ្ដាលហ្នឹងទេ?

សារិនៈ មិនដឹងជាគាត់មកពីខាងណាទេ ដឹងតែគាត់នៅខាង៩២០ ព្រោះកាលហ្នឹងគាត់នៅជាប់ជាមួយបង០៦ហ្នឹង?

ដានី: នៅជាប់គ្នា?

សារិនៈ ហើយម្យ៉ាងទៀត ឬក៏គាត់នៅជាមួយពូ ធៀវ តែម្ដងខ្ញុំមិនដឹងដែរកន្លែងហ្នឹង ព្រោះក្រោយពេលដែលខ្ញុំទៅនៅ៩២០ហ្នឹងឆ្នាំ៨៣-៨៤ ។

ដានីៈ កាលហ្នឹងគាត់ឈប់ធ្វើទាហានហើយមកនៅក្នុងកងពលមែនទេ?

សារិនៈ គាត់ដូចថានៅចំនុះមន្ទីរ ។

ដានីៈ នៅចំនុះមន្ទីរ?

សារិនៈ បាទ!

ដានីៈ មន្ទីរអីគេ មន្ទីររបស់តា ធៀវ ហ្នឹង?

សារិនៈ បាទ!

ដានីៈ ស្គាល់គាត់ច្បាស់ដែរ?

សារិនៈ គាត់គ្រប់គ្រងខាងផ្នែកសេដ្ឋកិច្ចហ្នឹងហ្នង ។

ដានីៈ គាត់គ្រប់គ្រងខាងផ្នែកសេដ្ឋកិច្ច?

សារិនៈ គាត់មើលការខុសត្រូវខាងផ្នែកសម្ភារៈ លុយកាក់ ហើយរបស់របរលក់ដូរអីហ្នឹង គ្រឿងហូបចុកអីគាត់ហ្នឹងហើយ អានេះគេហៅថាបង្កើតគ្រឿងពាណិជ្ជកម្មណា៎ ឬក៏គេហៅថារោងលក់ទំនិញ សហគមន៍អញ្ចឹងទៅណា៎ អញ្ចឹងខុះខាតអីត្រូវទិញគាត់ ។

ដានីៈ ទៅទិញគាត់?

សារិនៈ ហ្នឹងអើយ ។

ដានីៈ កាលហ្នឹងពូស្គាល់គាត់ច្បាស់តាំងពីហ្នឹងមក?

សារិនៈ ស្គាល់តាំងពីហ្នឹងមក ហើយពេលខ្លះលេងសើចជាមួយគាត់ទៅ គាត់ចេះតែសួរយើងទៅណាហើយយើងប្រាប់គាត់ថាយើងនៅជិតៗគ្នា ។

ដានីៈ កាលហ្នឹងគាត់ប្រាប់ថាគាត់នៅស្រុកណា?

សារិនៈ ថានៅស្រុកជិតៗខ្ញុំហ្នឹងឯង ស្រុកគាត់នៅចំបក់នៅអីអញ្ចឹងណា៎ ។

ដានីៈ នៅម្ដុំចំបក់?

សារិនៈ បាទ!

ដានីៈ ក្នុងស្រុកអីគេអាហ្នឹង?

សារិនៈ ស្រុកថ្ពងដែរហ្នឹង នៅស្រុកថ្ពងជាមួយខ្ញុំដែហ្នឹង ។

ដានីៈ ប៉ុន្តែពីមុនមកពូអត់ដែលស្គាល់គាត់ទេ?

សារិនៈ អត់ដែលស្គាល់ទេ ។

ដានីៈ  ប្រពន្ធគាត់ឈ្មោះអីទៅ?

សារិនៈ ប្រពន្ធឥលូវហ្នឹងឈ្មោះអ៊ឹ វ៉ាន់ ។

ដានីៈ  ចុះប្រពន្ធគាត់ពីមុន?

សារិនៈ ប្រពន្ធពីមុនអត់ដែលស្គាល់ផង ។

ដានីៈ  អញ្ចឹងប្រពន្ធឥលូវហ្នឹងប្រពន្ធគាត់ក្រោយទេ?

សារិនៈ បាទ!

ដានីៈ  ប្រពន្ធហ្នឹងគាត់យកពីអន្កាល់?

សារិនៈ យកតាំងពីយើងនៅក្នុងព្រៃហ្នឹងដែរ ។

ដានីៈ  តាំងពីពេលណាទៅ?

សារិនៈ តាំងឆ្នាំ៧៩ ប្រពន្ធគាត់ប្រហែលជាបែកបាក់គ្នាកាលយើងរត់វៀតណាមនោះ ពេលវៀតណាមចូលមកគាត់រត់ហើយប្រហែលជារត់បែកគ្នាហើយ នេះទៅនេះហើយមួយទៅនោះអញ្ចឹងទៅ គាត់រត់មកខាងព្រៃមក ហើយប្រពន្ធគាត់រត់ចូលទៅក្នុងភូមិទៅ ហើយដល់ក្រោយមកថាអត់ឃើញប្រពន្ធគាត់ ។

ដានីៈ  ប្រពន្ធដើមគាត់បាត់ទៅ ពូអត់ស្គាល់ទេប្រពន្ធដើមគាត់?

សារិនៈ អត់ស្គាល់ទេ ។

ដានីៈ  ហើយអ៊ឹ វ៉ាន់ ឥលូវគាត់នៅជាមួយគ្នា?

សារិនៈ នៅជាមួយគ្នា ហើយពូថាមានកូនមួយ គាត់មានកូនស្រីមួយ ។

ដានីៈ  កូនស្រី?

សារិនៈ បាទ!

ដានីៈ  កូនធំហើយ?

សារិនៈ ធំហើយ ។

ដានីៈ  អាយុប្រហែលជាប៉ុន្មានហើយ?

សារិនៈ អាយុប្រហែលកូនពៅខ្ញុំដែរហ្នឹង១៦ឆ្នាំ ។

ដានីៈ  ចុះកូនគាត់ពីមុនៗមក?

សារិនៈ កូនពីមុនឃើញនៅជាមួយគាត់២នាក់ ។

ដានីៈ  ឃើញកូននៅជាមួយគាត់២នាក់ដែរ?

សារិនៈ បាទ! តែប្រុសៗ ។

ដានីៈ  កូនពៅគាត់ឈ្មោះអីគេ?

សារិនៈ អត់បានស្គាល់ឈ្មោះទេ ។

ដានីៈ  ចុះប្រពន្ធគាត់ក្រោយនេះនៅក្មេងទេ?

សារិនៈ ចាស់ហើយ  អាយុប្រហែលជា៦០ហើយ ។

ដានីៈ  គាត់ឈ្មោះស្អី  រ៉ាន់?

សារិនៈ ឈ្មោះរុំ  រ៉ាន់ ។

ដានីៈ  ហើយតា  អាន  គាត់ឈ្មោះ...?

សារិនៈ ឈ្មោះអោម  អាន ។

ដានីៈ  គាត់អាយុប្រហែលៗគ្នាដែរ?

សារិនៈ បាទ!  ប្រហែលៗគ្នាដែរ ។

ដានីៈ  ឥលូវចាស់គាត់កាន់សិលអស់ហើយ?

សារិនៈ កាន់សិលអស់ហើយ  ទៅវត្តទៅវ៉ាអស់ហើយ ។

ដានីៈ  គាត់ទៅវត្តទៅវ៉ាហើយ?

សារិនៈ គាត់ទុកចំការស្រែឲ្យកូនគាត់ធ្វើ ។

ដានីៈ  អញ្ចា  សារិនៈ

ដានីៈ  អញ្ចឹងចំការស្រែគាត់ទុកឲ្យកូនគាត់ធ្វើ?

សារិនៈ បាទ!

ដានីៈ  គាត់ធ្វើអី  ឮថាគាត់ធ្វើគ្រូ?

សារិនៈ គាត់ចេះតែរកទៅដើម្បីបងប្អូន  រកថ្នាំចាស់  រកថ្នាំសសៃហ្នឹង  ហើយគាត់ចេះតែផ្សំទៅ ។

ដានីៈ  គាត់គ្រូខ្មែរ?

សារិនៈ បាទ!  គាត់មានគំនិតខ្លះ  ហើយគាត់បានសិក្សាខ្លះ  ដើមឈើដែលមានជាតិអីៗហ្នឹង  ហើយគាត់ចេះតែផ្សំៗគ្នាទៅ ។

ដានីៈ  ឮថាអ៊ំពូមីងគាត់ចេះថ្នាំខ្មែរ?

សារិនៈ ចេះច្រើនដែរ  តែគាត់មិនបើកមុខទេ  គាត់មិនផ្សាយឃោសនាទេ ។

ដានីៈ  គាត់ទៅសុំសិលនៅវត្តណា?

សារិនៈ នៅវត្តអូរដា ។

ដានីៈ  អ៊ំវត្តអូរដានៅខាងមុខនេះហ្នឹង?

សារិនៈ បាទ!

ដានីៈ គាត់អត់ធ្វើអាចារ្យទេ?

សារិនៈ អត់ទេ ចាស់ហើយ ។

ដានីៈ ចុះពូអញ្ចឹងពូនៅខាង៩៧០ហ្នឹងពី៨៥ ហើយកាលហ្នឹងពូរៀបការហ្នឹងពូរៀបនៅណាទៅ?

សារិនៈ នៅដងវែកហ្នឹងឯង ។

ដានីៈ នៅដងវែកហ្នឹងដែរ?

សារិនៈ បាទ!

ដានីៈ ពូរៀបការឆ្នាំ៨៧?

សារិនៈ បាទ!

ដានីៈ ពូរៀបការយ៉ាងម៉េចដូចថាពូរៀបការហ្នឹងយើងត្រូវគ្នាយើងរៀបការតាមប្រពៃណីឬក៏យ៉ាងម៉េចវិញ ។

សារិនៈ រៀបចំដូចថាតាមប្រពៃណីដែរ តែពេលនោះយើងក្រខ្សត់ណាស់ យើងគ្រាន់តែរកចាស់រកទុំមក ហើយត្រូវធ្វើពិធីតាមបែបបុរាណ តែយើងនៅខ្វះខាតផ្នែកសំលៀកបំពាក់ នៅខ្វះខាតផ្នែកសម្ភារៈផ្សេងៗទៀត មានតែភ្លេងដូចថាទ្រ ស្គរ ហើយអីផ្សេងៗលេងតាមបែបបុរាណហ្នឹង តែគេលេងកាត់ៗទេ ដើម្បីកុំឲ្យគេថាសម័យផ្តាច់ការពេក ហៅគ្នាមកដើម្បីឲ្យស្គាល់គ្នាទៅធ្វើបាញ់ដីនៀកមួយឆ្នាំងពីរឆ្នាំងទៅ ហើយមានអាចារ្យមានអីដេញពេលពេលវេលាទៅ ។

ដានីៈ ប៉ុន្តែកាលហ្នឹងដូចថាយើងបែកពីឪពុកម្តាយ បែកពីសាច់ញាតិអញ្ចឹងហើយចាស់ៗហ្នឹងចាស់ៗមកពីណាមក?

សារិនៈ ចាស់ៗហ្នឹងសុទ្ធតែមនុស្សដែលយើងតស៊ូទាំងអស់គ្នាហ្នឹង ។

ដានីៈ ដូចខ្ញុំនិយាយមេញថាអ៊ំ ប៉ូច ដូចតា អាន?

សារិនៈ ហ្នឹងអើយ ។

ដានីៈ គាត់ចូលរោងការយើងដែរ?

សារិនៈ ចូល ។

ដានីៈ កាលហ្នឹងប្រពន្ធពូគាត់ធ្វើអីទៅ?

សារិនៈ អត់មានធ្វើអីទេ គេហ្នឹងចេះតែដោយរោយមកតាមគេ គេបោកប្រាស់ គេនយោបាយថាសប្បាយថាអីអញ្ចឹងទៅណា៎ ។

ដានីៈ អញ្ចឹងគាត់មកពីខាងក្នុងមកទេ?

សារិនៈ ហ្នឹងអើយ មិនមែនគាត់តស៊ូជាមួយខ្ញុំទេ ។

ដានីៈ អញ្ចឹង?

សារិនៈ ហ្នឹងអើយ គាត់ចុះឡើងទៅតាមកងទ័ព ។

ដានីៈ ចុះកាលហ្នឹងពូធ្វើកងទ័ពពូមានឋានៈអីដែរ?

សារិនៈ ខ្ញុំកាលឆ្នាំ៨០ដល់ឆ្នាំ៩១គេឲ្យខ្ញុំនៅខាងវិទ្យុទាក់ទង ។

ដានីៈ នៅខាងវិទ្យុទាក់ទង?

សារិនៈ បាទ! តាំងពី៨០មករហូត

ដានីៈ ពូនៅកងពលណា?

សារិនៈ នៅកងពល៩៨០ហ្នឹងរហូតដល់ និយាយរួមខ្ញុំចូលតាំងពីឆ្នាំ៨០រហូតដល់៩១ ប៉ុន្តែគ្រាន់តែថាខ្ញុំនៅបានប្រហែលជា៦-៧ខែគេឲ្យខ្ញុំទៅកាន់តួលេខ ដល់ហើយកាន់តួលេខរហូត ។

ដានីៈ រហូតដល់ឆ្នាំ៩១?

សារិនៈ បាទ!

ដានីៈ ដល់ពេលឆ្នាំ៩១យ៉ាងម៉េចទៀតទៅ?

សារិនៈ ដល់ពេលឆ្នាំ៩១យើងវិលត្រលប់ពីដងរែកមកទីនេះ ហើយអត់មានធ្វើអីទេ ។

ដានីៈ មិនមែនពីដងរែកយើងមកអន្លង់វែងសិនទេ?

សារិនៈ អត់ទេ ពីអន្លង់វែងយើងមកទីនេះតែម្តង ។

ដានីៈ អញ្ចឹងបានន័យថាពី៩១ពូនៅអន្លង់វែង?

សារិនៈ បាទ! នៅអន្លង់វែងឈប់ហើយ ព្រោះខ្ញុំមានបញ្ហាសន្លាក់ជើងហើម ដល់ពេលអញ្ចឹងគេឈប់ឲ្យយើងធ្វើអីហើយ ។

ដានីៈ ត្រូវរបួសឬក៏យ៉ាងម៉េច?

សារិនៈ អត់ទេ យើងដើរទៅវាក្រលៀសហើមទៅ ។

ដានីៈ អញ្ចឹងយើងជម្ងឺដោយខ្លួនឯងទេ?

សារិនៈ បាទ! ជម្ងឺដោយខ្លួនឯង ។

ដានីៈ មិនមែន...?

សារិនៈ មិនមែនរបួស មិនមែនស្អីទាំងអស់ អត់ដែលរបួសទេខ្ញុំ បើរបួសៗតែចាក់ថ្នាំទេ ។

ដានីៈ របួសចាក់ថ្នាំ?

សារិនៈ បាទ! បើថារបួសហ្នឹងធ្វើសត្រូវហ្នឹងមិនដែលមានទេ ។

ដានី៖ អញ្ជឹងឆ្នាំណាដែលពូឈប់ហើយមកនៅអន្លង់វែង?

សារិន៖ ឆ្នាំ៩១ហ្នឹងយើងមានជម្ងឺហ្នឹងយើងឈប់ នៅក្នុងចន្លោះហ្នឹង៩០-៩១ហ្នឹង ពេលដែលខ្ញុំឡើងមកដល់ហ្នឹងចាប់ផ្តើមឈឺតែម្តង ចាប់ផ្តើមឈឺយើងគិតថាប្រហែលជាខែ១១-១២ហ្នឹង ។

ដានី៖ មកនៅអន្លង់វែង?

សារិន៖ បាទ!

ដានី៖ មកនៅអន្លង់វែងបានប៉ុន្មានទៅបានផ្លាស់?

សារិន៖ ខ្ញុំមកនៅបានតិចខែដែរហ្នឹង ។

ដានី៖ នៅបានតិចខែដែរ?

សារិន៖ នៅបានប្រហែលជា៧-៨ខែហ្នឹងបានផ្លាស់ កាល៩០យើងចុះពីដងរែកមកហើយមកនៅអន្លង់វែង ហើយចេញពីអន្លង់វែងឆ្នាំ៩១ នៅបានមួយឆ្នាំហ្នឹងហើយ ។

ដានី៖ កាលហ្នឹងអ៊ំៗ តាៗចុះមកនៅអន្លង់វែងទាំងអស់គ្នា?

សារិន៖ ចុះមកទាំងអស់ក្រោយពេលយើងមានកិច្ចព្រមព្រៀង ។

ដានី៖ មានកិច្ចព្រមព្រៀងឆ្នាំ៩១ហ្នឹងចុះមកនៅហ្នឹងទាំងអស់?

សារិន៖ មកនៅអន្លង់វែងទាំងអស់គ្នា ។

ដានី៖ ចុះមកនៅជុំគ្នាទាំងអស់គ្នាទៅ?

សារិន៖ មកនៅជុំគ្នា ។

ដានី៖ ច្រើនគ្រួសារទេ?

សារិន៖ ច្រើនណាស់ មួយកងពលមាន៣-៤-៥រយនាក់ ។

ដានី៖ ជាប្រពន្ធ ជាកូន ជាគ្រួសារ?

សារិន៖ បាទ!

ដានី៖ កាលនោះពូមានកូនប៉ុន្មាននាក់?

សារិន៖ មានកូន២នាក់ ។

ដានី៖ ចុះយ៉ាងម៉េចបានជាពូផ្លាស់ពីអន្លង់វែងមកនៅនេះ?

សារិន៖ អាហ្នឹងវាជាតម្រូវការរបស់ខាងលើ ហើយខ្ញុំគិតថាជាអ្នកជម្ងឺមួយដែរអញ្ជឹងមកពេទ្យតែម្តងទៅមកអង្គភាពពេទ្យ ។

ដានី៖ អង្គភាពពេទ្យយ៉ាងម៉េច?

សារិន៖ ពេទ្យរបស់តា ខៀវ ហ្នឹង ។

ដានី៖ អ៎! ពេទ្យរបស់តា ខៀវ?

សារិន៖ ហ្នឹងហើយ ។

ដានី៖ មកទាំងអស់គ្នាឬក៏មកខ្លះអត់ខ្លះ?

សារិន៖ និយាយរួមមួយមន្ទីរហ្នឹងមកទាំងអស់គ្នា ឲ្យតែមន្ទីរមកខាងតា ខៀវ មានអគ្គភាពពេទ្យ ហើយមានអគ្គភាពឃ្លាំង ហើយដូចបងមេឃុំហ្នឹងគាត់មិនអ្នកឃ្លាំង គាត់មើលការខុសត្រូវអគ្គរោបរយតោន ខាងគាត់ហ្នឹងមាន៩១០ ៧២០ ហើយមាន៣០២អីទៅ អាហ្នឹងខាងអ៊ំ ខៀវ ហើយខាងតា ម៉ុក មាន៩៨០ មាន៧៨៥ ហើយមានខាងឧត្តមានជ័យអញ្ចឹងទៅ ។

ដានី៖ ចុះកាលហ្នឹងអ៊ំ ប៉ូចហ្នឹងម៉េចបានជាគាត់មកនេះដែរ?

សារិន៖ ខ្ញុំគិតថាអានេះគេមកតាមតម្រូវការរបស់ខាងលើ យើងមានតម្រូវរបស់អ៊ំ ខៀវ ហើយឲ្យអ៊ំ ខៀវ គាត់ដូរមកនៅទីនេះដើម្បីជួយការងាររបស់អ៊ុំ ឈាន ។

ដានី៖ អ៊ុំ ឈាន ណា?

សារិន៖ អ៊ុំ ឈាន យើងនេះ ។

ដានី៖ អ៊ុំ ឈាន ខាងប៉ៃលិនហ្នឹង?

សារិន៖ បាទ! ឬក៏មកជួយខាងបង កន អញ្ចឹងទៅ ។

ដានី៖ នី កន?

សារិន៖ បាទ! តែគាត់មកគាត់នៅខាងមន្ទីរទេ គាត់នៅខាងបង កន នេះផ្ទះគាត់នៅនេះ គាត់មានផ្ទះតែគាត់អត់សូវមកនៅទេ គាត់នៅតែជាមួយនី កន ហ្នឹង ។

ដានី៖ នៅតំបន់នេះក្រែងពីមុនឯកឧត្តមសុខ គង់ គាត់គ្រប់គ្រងនៅទីនេះមែនទេ?

សារិន៖ គាត់គ្រប់គ្រងនៅនេះតែគាត់នៅក្រោមគេ ។

ដានី៖ នៅក្រោមគេ?

សារិន៖ បាទ!

ដានី៖ នី កន គាត់ធំជាង?

សារិន៖ ធំជាង ។

ដានី៖ ហើយបន្ទាប់ពីគាត់មកមានពីណាខ្លះទៀត?

សារិន៖ បន្ទាប់មកមាន ឃឹម មានបងអីចៅហ្វាយស្រុកសព្វថ្ងៃនេះ ហើយបានមកបងសុខ គង់អញ្ចឹងហូរហែរមក ។

ដានី៖ មានប៉ុន្មានកងពលនៅកំរៀងយើងនេះ?

សារិនៈ មានតែមួយកងពលទេ កងពលរបស់បង កនហ្នឹង ។

ដានីៈ អញ្ចឹងអ្នកដែលមកហ្នឹងយើងមកតាមមន្ទីររបស់តា ខៀវ មែនទេ?

សារិនៈ មកពីអន្លង់វែង៩១ហ្នឹងមកតាមរយៈអ៊ី ខៀវ ។

ដានីៈ ច្រើនដែរកាលហ្នឹង?

សារិនៈ កាលហ្នឹងមាន៣អង្គភាព អង្គភាពបើកបរ អង្គភាពឃ្លាំង ហើយនឹងអង្គភាពពេទ្យ មាន៣ អង្គភាពហ្នឹង ហើយមាន៥០០គ្រួសារ ។

ដានីៈ កាលហ្នឹងអ៊ំ ប៉ូច អីអត់មកទេ?

សារិនៈ អត់មកទេ ។

ដានីៈ ចុះតា អាន គាត់មកឆ្នាំណា?

សារិនៈ តា អាន មកពេលសាមារណេកម្មហើយហ្នឹង មកអន្លង់វែងហ្នឹងហើយមកពេលច្របូកច្របល់ ហ្នឹងទេដែលតា ម៉ុក យកតា ខៀវទៅសម្លាប់ ដល់ពេលតា ម៉ុក ធ្វើអញ្ចឹងបានច្របូកច្របល់ ហើយរត់គេចខ្លួនបាត់ ។

ដានីៈ ឆ្នាំ៩៧-៩៨?

សារិនៈ បាទ!

ដានីៈ គាត់មិនមែនមកជាមួយពូទេ?

សារិនៈ អត់ទេ គាត់មកក្រោយ ។

ដានីៈ គាត់មកក្រោយទេ ដោយសារច្របូកច្របល់ហ្នឹងដោយសារពាក់ព័ន្ធអញ្ចឹងទៅគាត់គេចខ្លួនទៅ បាត់ ។

សារិនៈ ចុះបើគេសម្លាប់ប្អូនថ្លៃរបស់គាត់ បង០៦ហ្នឹងប្អូនថ្លៃរបស់គាត់ ។

ដានីៈ បង០៦ហ្នឹងប្អូនថ្លៃគាត់ ប្អូនស្រីគាត់?

សារិនៈ ប្រពន្ធគាត់ហ្នឹងប្អូន ។

ដានីៈ ប្រពន្ធបង០៦?

សារិនៈ ប្អូនស្រីគាត់ ។

ដានីៈ យាយ លីន ហ្នឹងមែន?

សារិនៈ បាទ! ដល់ហើយគាត់គេចមកនេះ ។

ដានីៈ គេចនៅនេះរហូត?

សារិនៈ បាទ!

ដានី៖ ហើយអត់អីទេ គេអត់មានមកតាមទេ?

សារិន៖ អត់អីទេ ព្រោះគាត់គិតថានៅនេះដូចបងមេឃុំអីសុទ្ធតែជាអ្នកស្គាល់គ្នា សុទ្ធតែអ្នកស្គាល់ ហើយអ្នកស្គាល់គាត់ច្រើនណាស់ ដូចអ្នកអន្តភាពចាស់របស់អ៊ំ អាន ហ្នឹង ។

ដានី៖ នៅជាមួយគាត់កាលពីមុនហ្នឹង៣ឆ្នាំមែនទេ?

សារិន៖ បាទ!

ដានី៖ ហើយចុះឈ្មោះ ដុស ហ្នឹងគាត់នៅជាមួយតា អាន ដែរ?

សារិន៖ គាត់មេតា អាន ហ្នឹងទៀត អញ្ចឹងគាត់ជាផ្នែកសេនាធិការរបស់អ៊ំសុន សេន បានន័យកិច្ចការ អីបង ដុសហ្នឹងគាត់មកចាត់ចែងឲ្យថ្នាក់បង សឿន, បងលន អញ្ចឹងបង ដុស ហ្នឹងគាត់មេផ្ទាល់ពី ខាងលើមក ។

ដានី៖ ចុះពូតាំងពីពូផ្លាស់មកនៅហ្នឹងឆ្នាំ៩២ កាលហ្នឹងគេបែងចែកឲ្យពូនៅហ្នឹងឬក៏ពូជ្រើសរើសនៅហ្នឹង?

សារិន៖ តាមការពិតនៅហ្នឹងជាកន្លែងសហការណ៍ អញ្ចឹងការចែករំលែកនៅជាផ្ទះហើយរៀបចំភូមិ អញ្ចឹង យើងរុញធ្វើជាផ្លូវហើយ ហើយកាលនោះមានប្រដាប់រុញរបស់តាសុន សេន ដល់ហើយបានគេរុញ ទៅដុតអាហ្នឹង យើងនៅហ្នឹងអត់អស់ហ្នឹង បានគេអន្តន់ចែកគ្នាមួយគ្រួសារ៣០ម៉ែត្រឲ្យនៅ ។

ដានី៖ កាលនោះយើងនៅជារបៀបឯកជន គ្រួសារ ហើយរកហូបចុកខ្លួនឯងឬក៏យើងហូបរួម?

សារិន៖ ពេលនោះយើងគិតថាវាម្ចាស់ការហើយរឿងហូបចុក អញ្ចឹងអត់មានជំនួយអីទេ គេឲ្យយើងធ្វើស្រែ ខ្លួនឯង រកហូបខ្លួនឯង តែទៅធ្វើការរដ្ឋ អាហ្នឹងវាអញ្ចឹង អត់មានប្រាក់ ឧបត្ថម្ភ អត់មានសម្លៀក បំពាក់ឲ្យយើងទៀតទេឆ្នាំ៩២-៩៣ហ្នឹង វាដុតអំណោយហើយ អាហ្នឹងបើយើងនិយាយទៅវារឿងផ្ទៃក្នុងរបស់ខ្មែរក្រហម ដែលថាចែកប្រាក់ឲ្យមួយគ្រួសារ ប៉ុន្មានពាន់ៗអញ្ចឹងណា៎ ។

ដានី៖ បាទ!

សារិន៖ ហើយស័ក្តសីប៉ុន្មានសន្លឹកឲ្យយើងនៅ អញ្ចឹងមានតែប៉ុណ្ណឹងទេ ហើយយើងគិតថាគេគ្មឺម៉ែយើង ចែកឲ្យហើយលុយប៉ុន្មានពាន់បាតហើយមានស័ក្តសីពីបីសន្លឹក ហើយឲ្យយើងធ្វើការងារហ្នឹងរក ស៊ីចិញ្ចឹមជីវិត តែត្រូវតែរួមចំណែកតស៊ូការពារទឹកដី កាលសម័យនោះគេថាអញ្ចឹងរួមគ្នាតស៊ូ ការពារទឹកដី ទឹកដីយើងពីត្រឹមខ្សែនមកដល់ស៊ឹងបរិលយើងនេះ អាហ្នឹងទឹកដីរបស់ខ្មែរក្រហម ហើយ ។

ដានី៖ បាទ!

សារិន៖ អញ្ចឹងមានសិទ្ធការពារត្រឹមស៊ីងហ្នឹងទេ អត់មានចូលទៅក្នុងបានទេ ។

ដានី៖ អញ្ចឹងកាលហ្នឹងយើងចាប់ផ្ដើមធ្វើស្រែធ្វើចំការខ្លួនឯងពីឆ្នាំ៩២មកប្អូកអត់ទាន់ទេ?

សារិន៖ ធ្វើតាំងពី៩២មករហូតហ្នឹង ដាំស្រូវដាំអីហូប ។

ដានី៖ ហើយចុះគេចែករបបថាស័ង្កសី?

សារិន៖ បាទ! មានតែប៉ុណ្ណឹងឯង ។

ដានី៖ ហើយកាលជំនាន់នោះកាលឆ្នាំ៨២មិនមែនអីទេ?

សារិន៖ អត់ទេសុទ្ធតែព្រៃឬស្សីហ្នុង ហើយព្រៃឈើធំៗណាស់ នោះគល់វាច្រងើងច្រងាំងអញ្ចឹងទើបតែកាសចេញ ។

ដានី៖ ភូមិហ្នឹងទើបតែចេញជាវាលទេមែនទេ?

សារិន៖ អត់មានវាលទេ មើលទៅសុទ្ធតែព្រៃទាំងអស់ អញ្ចឹងយើងមកត្រួតត្រានេះរយៈពេល៣-៤ខែហ្នុង កាប់ហើយរើហើយបាននាំគ្នាមកសង់នៅកំប៉េកកំប៉ូក ល្អមើលណាស់ផ្ទះខ្មែរក្រហម សង់ផ្ទះតូចៗហ្នឹង ផ្ទះគាត់នោះបានសង់ស័ង្កសីបើកដែរហ្នឹង ផ្ទះហ្នឹងតាំងពីជំនាន់ហ្នឹង ។

ដានី៖ អាស័ង្កសីខាងក្រោយហ្នឹង?

សារិន៖ បាទ!

ដានី៖ ចុះផ្ទះពូអត់មានសង់ទេ?

សារិន៖ ខ្ញុំរុះចោលអស់ហើយ ។

ដានី៖ ដូចថាយើងចាប់ផ្ដើមយើងធ្វើកវែងកន្ទាំង តែយើងចាប់ផ្ដើមដូចថារីកធំធាត់ហ្នឹងតាំងពីពេលណា?

សារិន៖ ក្រោយពេលដែលយើងធ្វើសាមារណកម្មហើយហ្នឹង យើងចេះតែរៀបចំបណ្ដើរៗ ដល់ពេលហើយមានការទំនាក់ទំនងគ្នាជាមួយឯកឧត្ដមខាងបរិលហ្នឹងបាននាំគ្នាថាធ្វើផ្លូវខាងណា ហើយអាចទំនាក់ទំនងធ្វើយ៉ាងម៉េច ហើយបាននាំគ្នាធ្វើហ្នឹងឆ្នាំ៩៨ គេឈូសឆាយទៅតាមដំណើរផ្លូវផ្លូវរបស់ពួកខ្មែរក្រហមនាំគ្នារុញៗទៅ ហើយពេលមានកិច្ចព្រមព្រៀងមែនទែនទៅបានបងប្អូនខាងក្នុងចេះតែទំនាក់ទំនងស្គាល់បងប្អូនទៅ សុំដីសុំធ្លីចេះតែឲ្យនៅទៅ អង្គន់ចែកគ្នានៅទៅរហូតដល់ឆ្នាំ២០១១ហ្នឹងមានភូមិតភ្ជាប់គ្នាអញ្ចឹងទៅ តាមពិតដំបូងមកអត់មានទេ សុទ្ធតែព្រៃទាំងអស់ ។

ដានី៖ ចុះឈ្មោះភូមិឈ្មោះអីហ្នឹងយើងចេះតែដាក់បន្តបន្ទាប់ទៅ?

សារិនៈ គ្រាន់តែឃើញហេតុផលថាក្នុងភូមិនេះយើងយកស្ទឹងដែលជាមាររបស់ភូមិ យើងមានស្ទឹងខ្លះ ហើយឃើញមានអូរហើយមានគល់គគីច្រើនអញ្ចឹង ក៏នាំគ្នាដាក់ថាភូមិអូរគគីទៅ ។

ដានីៈ អ៎! អញ្ចឹងទេ?

សារិនៈ បាទ!

ដានីៈ យើងអ្នកដាក់ទេ មិនមែនមានឈ្មោះពីដើមមកទេ?

សារិនៈ តែបើអូរនេះបើនៅក្នុងដែនទីគេហៅថាអូររុន តែយើងអត់ដឹងយើងក្រោយឃើញថាគេអ្នកនៅចាស់គេហៅថាអូររុន ហើយយើងមកនៅថ្មីយើងឃើញគល់គគីច្រើននៅតាមអូរដែលពួកខាងថៃគេមកកាត់ហ្នឹងហើយអត់លក់ឲ្យថៃ អញ្ចឹងយើងហៅថាអូរគគីទៅ ។ ហើយភូមិស្វាយជ្រុំនៅមាត់អូរនោះមានភូមិចាស់គេមួយ មានស្វាយរបស់យើងហ្នឹងឃើញមានដើមធំៗពីរបីដើមមួយជុំ ហើយក៏គេដាក់ស្វាយជ្រុំទៅ ភូមិកណ្ដាលរបស់មេភូមិខាងនេះគេ ខាងនោះគាត់អញ្ចឹងទៅហើយគាត់នៅកណ្ដាលគេហៅភូមិកណ្ដាលអញ្ចឹងទៅ បានន័យថាគាត់នៅកណ្ដាលគេអញ្ចឹងទៅ ។

ដានីៈ ចុះពូបានទៅលេងស្រុកកំណើតឆ្នាំណា ឆ្នាំដំបូងដែលពូបានទៅមុនគេ?

សារិនៈ ឆ្នាំ៩៨ កាលហ្នឹងខ្ញុំទៅលេងផ្ទះយ៉ាប់ណាស់ មិនមែនជិះឡានដូចឥលូវនេះទេ ឡើងទៅតាមនេះទៅម៉ាឡៃទៅទិញកូនជីរ ហើយទៅដល់បាត់ដំបងចង់ចេញក្លួតហើយផ្លូវយើង ។

ដានីៈ ទៅលេងផ្ទះលើកទីមួយ?

សារិនៈ បាទ!

ដានីៈ ដល់ពេលទៅដល់ផ្ទះបងប្អូន ឪពុកម្ដាយ..?

សារិនៈ ឪពុកស្លាប់ ។

ដានីៈ ម្ដាយ?

សារិនៈ ម្ដាយនៅ ។

ដានីៈ គាត់មើលពូស្គាល់ទេ បែកពូយូហើយ?

សារិនៈ គាត់នៅចាំបាន ។

ដានីៈ គាត់នៅចាំបានដែរ?

សារិនៈ បាទ! គាត់មើលស្ទាកស្ទាម គាត់ក្រឡេកមើលស្គាល់តែម្ដង ដល់ពេលអញ្ចឹងគាត់រៀបរាប់ដំណើររឿងតែស្គាល់ថែមទៀត ។

ដានីៈ ពូនៅចាំផ្ទះច្បាស់ដែរ?

សារិនៈ ច្បាស់ ។

ដានី៖ ពូទៅរកឃើញដែរ?

សារិន៖ ឃើញ ។

ដានី៖ ពូអញ្ចឹងបងប្អូនញាតិមិត្តអីនៅចាំនៅស្គាល់ពូដែរ?

សារិន៖ អត់ទេ ភ្លេចខ្លះហើយ ហើយសូម្បីតែប្អូនហ្នឹងក៏អត់ស្គាល់ដែរ ដែលខ្ញុំចេញមកគេទើបតែធំណាស់ ហើយប្អូនពីរនាក់ដែលប៉ុនៗ យើងធ្លាប់ដឹងចិត្តគ្នា ហើយអាពីរនាក់នោះវាអត់ដឹងថាខ្ញុំជាអ្នកណាផង ដល់ពេលម៉ែប្រាប់ថាពេលដែលឯងចេញទៅអញបានពីរនេះទៀត ហើយអាពីរនាក់ហ្នឹងក៏វាអត់គិតថាយើងបងវាដែរ ។

ដានី៖ ចុះពូទៅលេងផ្ទះបានយូទេ?

សារិន៖ ទៅអត់យូទេ ព្រោះប្រញាប់មកវិញដែរ ។

ដានី៖ អ៎!

សារិន៖ កាលហ្នឹងទៅបាន៩ថ្ងៃ ។

ដានី៖ ចុះដឹបូងៗពូអត់ចង់ទៅនៅស្រុកកំណើតទេ?

សារិន៖ ទៅនៅស្រុកកំណើតវាពិបាករស់នៅ មើលទៅមុខរបរវាអត់មានអីក្រៅពីធ្វើស្រែទេ ហើយបើយើងធ្វើតែស្រែហើយឡើងត្នោតហ្នឹងដូចជាមិនរស់ទេ ព្រោះវាលំបាក ហើយដីវាតិច ហើយម្តាយឪពុកចែកឲ្យប្អូនៗអស់ទៅវាអត់មាន សល់ដីតិចតួចហ្នឹងខ្ញុំមិនចង់បានទេ ព្រោះដីខ្ញុំធំជាងគេ ម៉ែមិនចាំបាច់ទុក មិនចាំបាច់ប្រគល់ឲ្យខ្ញុំទេឲ្យទៅប្អូនៗទៅ ។ ដូចថាអ្វីដែលយើងចោលគាត់ជាង៣០ឆ្នាំហើយយើងយករបស់គាត់យ៉ាងម៉េចកើត អញ្ចឹងយើងគិតថាយើងរកខ្លួនឯងទៅ ។

ដានី៖ ប៉ុន្តែពូគិតថាពូរស់នៅនេះយូ ហើយដូចថានៅនេះវាស្និទ្ធស្នាលជាងនៅស្រុកកំណើតឬក៏ម៉េច?

សារិន៖ ខ្ញុំគិតថាវាស្និទ្ធស្នាល ដូចថាវាមិនស្រដៀងគ្នាហើយក៏វាមិនខុសគ្នាប៉ុន្មានដែរ តែដូចថាធម្មតាយើងនៅកន្លែងនេះមិនមែនជាសាច់ញាតិបងប្អូនយើងក៏ពិតមែន តែដូចថាវាមានការទំនាក់ទំនងទូលាយ ប៉ុន្តែដល់ពេលទៅនៅស្រុក អញ្ចឹងដល់ពេលទៅនៅស្រុកអ្នកស្រុកគេមើលមកខ្ញុំថាខ្ញុំអ្នកអញ្ចឹងណាស់ ។

ដានី៖ បាទ!

សារិន៖ អញ្ចឹងការទំនាក់ទំនងរបស់យើងហើយហ្នឹងអ្នកស្រុកវាមិនសូវមាន ហើយក៏វាមិនសូវទូលាយដែរ ។

ដានី៖ វាមិនស្និទ្ធស្នាល?

សារិនៈ ហ្នឹងហើយ ដល់ពេលអញ្ចឹងយើងគិតថាអញ្ចឹងក៏អញ្ចឹងទៅ សរសើរតែបងប្អូនយើងក៏បានដែរ អ្នកស្រុកគេមិនសរសើរក៏អត់ទៅ តែគេដឹងថាយើងនេះជាកូនអ្នកនេះកូនអ្នកនោះហើយ តែភាពស្និទស្នាលហ្នឹងវាអត់មានទេ ។

ដានីៈ អញ្ចឹងពូទៅហ្នឹងនឹកខាងនេះ?

សារិនៈ នឹកនេះជាងនោះហើយ ។

ដានីៈ ពូទៅបានប៉ុន្មានដងហើយ?

សារិនៈ ទៅបាន៦ដងហើយ ។

ដានីៈ ច្រើនដែរ?

សារិនៈ ញឹកដែរហើយ ។

ដានីៈ ចុះពូបើយើងប្រៀបធៀបទៅ កាលពីមុនសាមារណកម្មហើយក្រោយសាមារណកម្មយ៉ាងម៉េចដែរ វាខុសគ្នាយ៉ាងម៉េចទៅអ្នកស្រុកភូមិយើងនេះ?

សារិនៈ ខុសគ្នាដូចមេឃហើយនឹងដីបើយើងគិតទៅ គិតថាក្រោយពេលដែលយើងសាមារណកម្មហើយ យើងទូលាយយើងសប្បាយចិត្ត សប្បាយត្រង់ថាយើងមានអ៊ីគ្រប់យ៉ាង មានជម្រកជ្រកកោនស្រួលបួល មានដីធ្លីធ្វើបបូរ មានរបស់របរប្រើប្រាស់ ដូចថាវាមិនគ្រប់គ្រាន់តែវាល្អមនឹងយើងអាចធ្វើទៅបាន កាលពីមុនយើងបាតដៃទទេគ្មានកង់គ្មានម៉ូតូ តែឥលូវលែងចង់ជិះកង់ចង់ជិះតែម៉ូតូទៀត ហើយរបស់ប្រើប្រាស់យើងចង់បានអីក៏មានគ្រប់បែបយ៉ាង កាលលើកមុនយើងមានតែផ្លូវតែឥលូវមានភ្លើងទៀត អញ្ចឹងបានថាវាអភិវឌ្ឍន៍ តំបន់នេះជាតំបន់មួយដែលមិនអាចនឹកស្មានដល់ដូចថាវាបានដល់ប៉ុណ្ណឹង តែបើយើងមើលទៅស្រុកកំណើតរបស់យើងវិញដែលផ្តល់កំណើតឲ្យយើងបានមកដល់ប៉ុណ្ណេះហើយយើងវិលទៅមើលវាវិញហាក់ដូចថាភាពនៅចាស់ដដែលដូចថាវាអត់ថ្មីសោះ វាអត់ថ្មីទេវានៅចាស់ដដែល ។

ដានីៈ ប៉ុន្តែមួយទៀតដែលខ្ញុំធ្លាប់បានជួបពូមីងមួយចំនួនតូចគាត់ថា សួគាត់ទាក់ទងនឹងបញ្ហាហ្នឹងថាកាលពីមុនសាមារណកម្មគាត់រស់គាត់មិនចាំបាច់ភ័យព្រួយទៅរកអី ទៅធ្វើអីដើម្បីបានអង្ករបានអីមកហូប កាលពីមុនមានរបបមានអីគេចែកឲ្យយើង គិតថាត្រៀមប្តុក៏វៃអញ្ចឹងទៅ តែម្ហូបហូបចុកមិនខ្វះទេ យើងហូបបបូរ តែឥលូវបើយើងមិនប្រឹងប្រែងរកទេ ហើយយើងអត់មានដីធ្លីថាគាត់មិនដឹងបានអីហូប អានេះយ៉ាងម៉េចដែរ?

សារិនៈ តាមការពិតគាត់យល់ច្រឡំផ្សេង គាត់គិតថានេះជាការនិយាយរបស់គាត់ អាហ្នឹងគាត់គិតពីឆ្នាំណាមកហើយគាត់គិតពីត្រឹមណាទៅវិញទេ អញ្ចឹងគាត់និយាយថាពីឆ្នាំណាមកមុខហើយពីឆ្នាំណា

ទៅក្រោយវិញ អញ្ចឹងអាទៅក្រោយនោះជាពាក្យសំដីដែលគាត់ថាស្រួល គាត់ហូបស្រួល គាត់ដេកស្រួល សម្លៀកបំពាក់ក៏ស្រួលអញ្ចឹងទៅ អាហ្នឹងវាចែកដាច់ពីគ្នា គាត់អត់យល់ថាអ៊ីទៅជាសាមារណកម្ម អ៊ីទៅដែលជាកិច្ចព្រមព្រៀង បានន័យថាគាត់អត់យល់ពីពាក្យហ្នឹងទេ តែបើសិនជាគាត់យល់គាត់គិតថាគាត់ចេះបែងចែកអ៊ីដែលគាត់និយាយហើយ គាត់និយាយពីត្រឹមណាមកមុខហើយពីត្រឹមណាមកក្រោយ តាមការពិតគាត់បានស្រួលមែនកាលពីមុននោះ អញ្ចឹងអគ្គិមានស្រាប់ហើយអីៗក៏មានស្រាប់ អាហ្នឹងតាំងពីឆ្នាំ៩០ទៅក្រោយ អញ្ចឹងពី៨៩ទៅក្រោយឬក៏ឆ្នាំ៩០ទៅក្រោយចុះវាស្រួលមែន ឲ្យតែដល់ខែគេបើកហើយដូចជាអង្ករ បើកប៊ីចេង បើកអំបិល បើកប្រហុកអញ្ចឹងទៅ តែចាប់ពីឆ្នាំ៩០-៩១មកមិនអាចបើកបានទៀតទេ ព្រោះនៅលើសកលលោកគេផ្ដាច់ជំនួយហើយ អញ្ចឹងកាលពីឆ្នាំ៨៩មកក្រោយគេនៅមានជំនួយ យើងនៅគាំទ្រខ្មែរក្រហម ដល់ពេលមានកិច្ចព្រមព្រៀងជាមួយប៉ារីសហើយគេផ្ដាច់ជំនួយទាំងអស់ អញ្ចឹងខ្ញុំគិតថាអ៊ីដែលគាត់និយាយគឺចាប់ពី៨៩មកក្រោយទេ ។

ដានី៖ បាទ! ចុះបើតាមពូយល់ពី៨៩ទៅក្រោយហ្នឹងយើងមានរបបមានអីមែនតែវាមានសេរីភាពមានអីទេ?

សារិន៖ អត់ស្រួលទេ គាត់គិតថាហូបចុកស្រួលតែយើងគិតថាវាអត់មានសេរីភាព តែពិបាកថាព្រោះគាត់មើលឃើញថាស្រួលម្យ៉ាងៗម្នាក់អញ្ចឹងណា៎ អាហ្នឹងដោយសារអីដោយសារគាត់មានកូនតូច គាត់មានកូនបន្ទាប់ទៀត ហើយគាត់មានត្រូវការទៅណា តែការនិយាយហ្នឹងអ្នកដែលមិនធ្វើអីទេដឹងបានគេអត់ហាម តែអ្នកដែលនិយាយអញ្ចឹងប្រហែលជាកន្លែងដែលគេរស់នៅហើយគេមានដំណែងធំអញ្ចឹង គាត់អត់ត្រូវរវល់ធ្វើអីទេ ចង់អ្នកឯងបិទចំរូង ចង់អ្នកឯងចាក់ចំរូងដឹកជញ្ជូនអីគាត់អត់បានដឹងគាត់និយាយអញ្ចឹងទៅវាស្រួលហើយ តែបើសិនជាយើងគិតថាចុះមកតាមអគ្គភាពគិតថាលំបាកគ្រប់យ៉ាង អញ្ចឹងគេកំណត់ឲ្យស្ត្រីក្នុងមួយថ្ងៃគេឲ្យយើងបិទចំរូងហ្នឹងឲ្យបាន៥០០ដើម មិនមែនហូបស្រួលដេកស្រួលដូចគាត់ថានោះទេ មិនមែនជារឿងស្រួលទេ អញ្ចឹងយើងហូបស្រួលមែន ស្លៀកពាក់ស្រួលមែន តែមិនអាចស្រួលដូចគាត់ថានោះទេ អ្នកដែលស្រួលពេកគឺជាគ្រួសារកម្មាភិបាល ។

ដានី៖ គ្រួសារកម្មាភិបាល?

សារិន៖ បាទ! អញ្ចឹងគ្រួសារកម្មាភិបាលហ្នឹងស្រួលមែន ព្រោះគេចង់និយាយថាបើសិនជាគេមិនឲ្យយើងរស់ក៏បាន ឲ្យយើងស្លាប់ក៏បានជារឿងរបស់គេ ។

ដានី៖ សំនួរចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់ដឹងពីយោបល់របស់លោកពូវិញ ដូចថាលូវនេះយើងមានខាងរាជរដ្ឋាភិបាលហើយនឹងអង្គការសហប្រជាជាតិបង្កើតតុលាការមួយ ហៅថាតុលាការជំនុំជំរះកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយឥលូវហ្នឹងដូចករណីរបស់គាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលគាត់ជាអតីតប្រធានមន្ទីរស-២១ហៅគុកទួលស្លែងហ្នឹងគេបានជំនុំជំរះហើយ ហើយក្នុងឆ្នាំហ្នឹងប្រហែលជាប៉ុន្មានខែទៅមុខទៀតហ្នឹងចាប់ផ្ដើមជំនុំជំរះករណី០០១ ដែលមានមេដឹកនាំខ្មែរក្រហមដូចជា នួន ជា, អៀង សារី ប្រពន្ធរបស់គាត់ ហើយនឹងខៀវ សំផន ហើយបើតាមយោបល់របស់ពូផ្ទាល់ ពូយល់ឃើញថាការបង្កើតតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមជាការត្រឹមត្រូវឬក៏មិនត្រឹមត្រូវទេ បើតាមយោបល់របស់ពូ?

សារិនៈ នេះជាការមិនសមហេតុសមផលមួយដែលយើងគួរឲ្យអាណោចអាធម៌ ក្នុងសម័យនោះបើយើងនិយាយទៅយើងមិនប្រកាន់ថាបុគ្គលណាឬបុគ្គលណាទេ វាជារឿងនយោបាយតែមិនដឹងថាអ្នកណាខុសអ្នកណាត្រូវនោះទេបើយើងមើលតាមការជាក់ស្ដែងអញ្ចឹងណា អញ្ចឹងខាងលើអនុវត្តតាមបែបសប្បាយៗ ប៉ុន្តែបើចុះមកខាងក្រោមហ្នឹងដូចថាយកបញ្ហាខាងលើសប្បាយហ្នឹងយកមកបំប្លែងថាមិនឲ្យសប្បាយអញ្ចឹងទៅ ឲ្យឧទាហរណ៍ដូចថាការហូបចុកខាងលើគេកំណត់ថាហូបឲ្យគ្រប់គ្រាន់ ហូបចេះសន្សំសំចៃ ពាក្យថាហូបឲ្យគ្រប់តែសន្សំសំចៃ ពាក្យសន្សំសំចៃនេះដូចសម្ដេចហ៊ុន សែនគាត់មានប្រសាសន៍ចែកជាឯកសារអញ្ចឹងដែរ "ចេះមកពីរៀន មានមកពីរក" អញ្ចឹងសម្ដេចភាសានេះជាភាសាមួយចាស់គម្រិល អញ្ចឹងគេថាចង់ចេះត្រូវតែខំរៀន ចង់មានត្រូវតែខំរក វាមាន៥ចំនុចរបស់គាត់ ចេះចាយចេះរក ចេះសន្សំចេះសន្សំសំចៃ អាហ្នឹងច្បាប់គាត់ក្រោយ គាត់ថាចេះមកពីរៀនមានមកពីរកហ្នឹង អាហ្នឹងពាក្យចាស់យូហើយតួតែយើងកុំប្រើ ព្រោះខ្ញុំគិតថាចេះមកពីរៀនមានមកពីរកនោះ អញ្ចឹងក៏វាល្អដែរ ប៉ុន្តែឥលូវគាត់មានដល់ទៅ៥ ចេះរកចេះចាយ ចេះសន្សំចេះសន្សំសំចៃ ចេះសន្សំហើយចេះសន្សំសំចៃទៀតអាហ្នឹងបានមានៗ

ដានី៖ អញ្ចឹងយ៉ាងម៉េចទៅសរុបរួមមក?

សារិនៈ អញ្ចឹងខ្ញុំគិតថាជាការល្អដែរដើម្បីកុំឲ្យមនុស្សមានដំណែងមានអំណាចហ្នឹងចេះតែប្រព្រឹត្តនូវទង្វើដែលបុគ្គលដទៃទៀតយល់ថាខ្លួនជាអញអញ្ចឹងណា៎ អញមានអំណាច អញ្ចឹងបើសិនជាគិតថាម្នាក់អំណាចគាត់ធំជាងគេនោះ អញ្ចឹងអ្នកផ្សេងទៀតមិនអាចទៅធ្វើអីបានទេ មិនអញ្ចឹងមែនទេ?

ដានី៖ បាទ!

សារិនៈ អញ្ចឹងដូចនៅក្នុងតំបន់នេះអញ្ចឹង អ្នកមានអំណាចហ្នឹងអ្នកផ្សេងធ្វើអីអត់បានទេ អញ្ចឹងអ្នកមានអំណាចហ្នឹងគាត់ចង់មកធ្វើកន្លែងណាក៏ជារឿងរបស់គាត់ គាត់ថារបស់អញគឺអញហើយ បើថាគាត់ឲ្យគឺបាន បើថាអញមិនឲ្យឯងទេគឺអត់បានទេ អាហ្នឹងយើងជៀសវៀងបញ្ហាហ្នឹង ហើយម៉្យាងទៀតដូចថាយើងអត់មានសិទ្ធសេរីភាពអីទេ ធ្វើអ្វីៗតាមតែតម្រូវរបស់គេ អញ្ចឹងយើងគិតម៉្យាងវាជាតម្រូវ ហើយម៉្យាងទៀតខ្ញុំគិតថាដូចគាត់ៗធ្វើទៅតាមបទបញ្ជាខាងលើដែរ បើបទបញ្ជាៗទៅហើយគាត់មិនអនុវត្តមិនខុសពីសម្តេចហ៊ុន សែនបញ្ជាទៅក្រសួងស្នាក់ការអញ្ចឹងថាឲ្យកាត់ទ្រុងឡាន ទ្រុងឡានដែលវាធំហើយវែងហួសហេតុត្រូវតែកាត់ តែក្រសួងទីស្នាក់ការគាត់អត់បានធ្វើ អញ្ចឹងសម្តេចហ៊ុន សែនថាត្រូវតែដកចោលទៅបើឯងមិនធ្វើ បើសិនជាខ្ញុំយល់ណា៎ អញ្ចឹងមិនខុសអីពីបញ្ជាការខាងលើទេ ដូចថា ឌុច ធ្វើការហ្នឹងឯងត្រូវតែសម្លាប់ បើមិនសម្លាប់ទេគឺមិនបានទេ នេះជាបញ្ជាអញ្ចឹងយើងបញ្ហាហ្នឹងមកថ្ងៃថ្ងៃ អាមួយបញ្ជាឲ្យកាត់ឡានមិនមែនឲ្យកាត់កមនុស្សទេ ឲ្យកាត់ឡានហើយថែរក្សាផ្លូវឲ្យមានគង់វង្សភាពសម្រាប់ចៅគាត់ទៀត ចៅគាត់មិនទាន់ធ្វើឃើញទេនូវអ្វីដែលគាត់បានធ្វើនោះខ្ញុំគិតថាអញ្ចឹង តែវាជាការងារល្អដែរសម្រាប់អ្នកក្រោយ កុំឲ្យមនុស្សជំនាន់ក្រោយហ្នឹងអត់ដឹងថាជំនាន់ប៉ុល ពត ហ្នឹងយ៉ាងម៉េច គេកាប់សម្លាប់យ៉ាងណាអីយ៉ាងណាអត់ដឹងទេ កូនចៅយើងជំនាន់ក្រោយអត់ដឹងទេ អត់ដឹងថាប្រវត្តិរបស់ខ្មែរយើងលំបាកយ៉ាងនាត. ហើយវាសំណាងល្អដែរ គ្រាន់ថាធ្វើនេះធ្វើដើម្បីឲ្យក្មេងជំនាន់ក្រោយដឹងថាកាលពីមុនមកនោះវាមានការលំបាកអញ្ចឹង មិនមែនរឿងស្រួលទេ ។

ដានីៈ អញ្ចឹងខ្ញុំដូចជាអស់សំនួរអីត្រូវសួនាំលោកពូទៀតហើយ ពូមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំមិនទាន់បានសួរពូទេ?

សារិនៈ ដូចជាអត់មានអីបន្ថែមទេ តែបើយើងគិតថាបន្ថែមទៅក៏វាអត់មានអីជាងហ្នឹងទេ ទាំងការអភិវឌ្ឍន៍ ទាំងការអប់រំសាសនា អញ្ចឹងយើងមានទាំងអស់ និយាយរួមមានគ្រប់យ៉ាងក្នុងសង្គមរបស់យើង បច្ចុប្បន្នយើងមានចង់រៀនមុខអីក៏បាន ធ្វើអីក៏បាន អាហ្នឹងតាមសិទ្ធរបស់យើងព្រោះមានគ្រប់យ៉ាងអស់ហើយ ។

ដានីៈ អញ្ចឹងខ្ញុំអរគុណពូច្រើនដែលបានចំនាយពេលជួបសំណេះសំណាលជាមួយខ្ញុំអំពីររឿងរ៉ាវក្នុងជីវិតរបស់លោកពូ អញ្ចឹងខ្ញុំសូមអរគុណច្រើន ។

សារិនៈ បាទ!